# របាយការណ៍សិទ្ធិមនុស្ស ប្រចាំឆ្នាំ២០១១ ប្រទេសកម្ពុជា

1

## សេចក្តីសង្ខេប

ប្រទេសកម្ពុជាប្រកាន់របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដោយមានទម្រង់រដ្ឋាភិបាលសភានិយមតាមរយៈ ការបោះឆ្នោត។ នៅក្នុងការបោះឆ្នោតជាតិ ដែលបានរៀបចំឡើងកាលពីឆ្នាំ២០០៨ នាពេលថ្មីៗនេះ គណបក្សប្រជាជនកម្ពុជា (CPP) បានឈ្នះចំនួន ៩០អាសនៈលើ ១២៣អាសនៈ នៅក្នុងរដ្ឋសភា។ អ្នកសង្កេតការណ៍ ភាគច្រើនបំផុតបានវាយតម្លៃថា ដំណើរការបោះឆ្នោតមានការកែលម្អជាងពីការបោះឆ្នោតកន្លងទៅ ប៉ុន្តែ ពុំបានបំពេញតាមស្តង់ដារអន្តរជាតិទាំងស្រុងនៅឡើយ។ គណបក្សប្រជាជនកម្ពុជាបានពង្រឹងការគ្រប់គ្រងលើផ្នែកទាំង ៣ នៃស្ថាប័នរដ្ឋាភិបាល និងស្ថាប័នជាតិផ្សេងៗទៀត ដោយអំណាចភាគច្រើនបំផុតប្រមូលផ្តុំនៅក្នុងដៃរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន។ កងកម្លាំងសន្តិសុខស្ថិតនៅក្រោមចំណុះរបស់អាជ្ញាធរស៊ីវិល។

ប្រព័ន្ធតុលាការទន់ខ្សោយ ដែលពេលខ្លះ ខកខានពុំបានផ្តល់ការកាត់ក្តីតាមដំណើរការត្រឹមត្រូវ និងយុត្តិធម៌នោះ គឺជាបញ្ហាសិទ្ធិមនុស្សនាំមុខគេមួយ។ តុលាការខ្វះខាតធនធានមនុស្ស និងហិរញ្ញវត្ថុ ព្រមទាំងស្ថិតក្រោមឥទ្ធិពលអំពើពុករលួយ និងនយោបាយ។ អប្រសិទ្ធភាពរបស់តុលាការក្នុងការកាត់សេចក្តីវិវាទដីធ្លីដែលកើតចេញពីការផ្តល់សម្បទានដីសេដ្ឋកិច្ចរបស់រដ្ឋាភិបាល រួមទាំងការផ្តល់ដីឱ្យទៅមន្ត្រីរបស់គណបក្សកាន់អំណាចផងដែរ បានជំរុញឱ្យមានវិវាទកាន់តែខ្លាំងឡើង ជូនកាល នាំឱ្យមានអំពើហិង្សានៅគ្រប់ខេត្តផងដែរ។ ការបន្តចាត់ទុកករណីបរិហារកេរ្តិ៍ និងការផ្សព្វផ្សាយព័ត៌មានមិនពិត ជាករណីព្រហ្មទណ្ឌ និងការបកស្រាយយ៉ាងទូលំទូលាយនូវការញុះញុងជាករណីព្រហ្មទណ្ឌ បានបង្កជាការរឹតត្បិតសេរីភាពបញ្ចេញមតិ។

តាមរបាយការណ៍ មានសមាជិកកងកម្លាំងសន្តិសុខ បានប្រព្រឹត្តឃាតកម្មតាមអំពើចិត្ត។ អ្នកជាប់ឃុំ ត្រូវបានរំលោភបំពាន ជារឿយៗ ដើម្បីបង្ខំឱ្យសារភាព ចំណែកឯស្ថានភាពពន្ធនាគារវិញមានសភាពយោរយៅ។ អ្នកឃ្លាំមើលសិទ្ធិមនុស្ស បានរាយការណ៍អំពីការចាប់ខ្លួនទាំងបំពាន និងការឃុំខ្លួនមុនពេលកាត់ក្តីហួសពេល កំណត់។ មានពេលខ្លះ រដ្ឋាភិបាលបានជ្រៀតជ្រែកចំពោះសេរីភាពប្រមូលផ្តុំ។ អំពើពុករលួយនៅតែមានសភាព រីករាលដាល ហើយតាមរបាយការណ៍ ស្ថាប័នសិទ្ធិមនុស្សរបស់រដ្ឋាភិបាល នៅតែគ្មានប្រសិទ្ធភាព ចំណែកឯការរើសអើង និងការជួញដូរស្ត្រី និងកុមារ នៅតែកើតមានជាបន្ត។ អំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពាន លើកុមារនៅកើតមានឡើង ចំណែកឯការអប់រំកុមារពុំទាន់មានភាពគ្រប់គ្រាន់នៅឡើយទេ។

រដ្ឋាភិបាលបានធ្វើការដាក់ទោសមន្ត្រីដែលបានប្រព្រឹត្តអំពើរំលោភបំពាន ប៉ុន្តែ ភាពគ្មានទោសពៃរ៍ចំពោះអំពើពុករលួយ និងការរំលោភបំពានផ្សេងៗទៀត នៅតែមានជាបន្ត។

**ផ្នែកទី១៖ ការគោរពសេចក្តីថ្លៃថ្នូរបុគ្គលរួមមានសេរីភាពរួចផុតពី៖**

## ក. ការដកហូតជីវិតដោយរំលោភបំពាន ឬដោយខុសច្បាប់

មានរបាយការណ៍ជាច្រើនថា កងកម្លាំងសន្តិសុខបានប្រព្រឹត្តអំពើឃាតកម្មដោយរំលោភបំពាន ឬខុសច្បាប់។ ឧទាហរណ៍ កាលពីថ្ងៃទី០៨ ខែមីនា មន្ត្រីនគរបាលដែលដឹកនាំដោយលោក គឹម រឹទ្ធ ដែលនៅពេលនោះ ជាអធិការនគរបាលស្តីទី នៅស្រុកសំឡូត ខេត្តបាត់ដំបង បានបាញ់សម្លាប់ ឈ្មោះ ឡេង រិន នៅអំឡុងពេលប៉ុនប៉ងចាប់ខ្លួនមួយ។ តុលាការខេត្តបានបញ្ជាឱ្យនគរបាលនាំឈ្មោះ ឡេង ទៅកាន់តុលាការ ដើម្បីសាកសួរអំពីករណីឃាតកម្ម។ នគរបាលបានអះអាងថា ឈ្មោះ ឡេង ត្រូវគេបាញ់ នៅពេលតបតនឹងការចាប់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ បានចោទប្រកាន់ថា នេះជាករណីឃាតកម្មខុសច្បាប់ និងបានជួយគ្រួសារជនរងគ្រោះដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌប្រឆាំងនឹងមន្ត្រីនគរបាលទាំងនោះ។ មកដល់ដំណាច់ឆ្នាំនេះ សំណុំរឿងនេះ ពុំទាន់បានដោះស្រាយនៅឡើយទេ ចំណែកឯកាលបរិច្ឆេទសម្រាប់កាត់ក្តីក៏ពុំទាន់បានកំណត់នៅឡើយដែរ។ លោក គឹម រឹទ្ធ នៅតែមានសេរីភាព និងនៅបំពេញភារកិច្ចជាអធិការនគរបាលស្តីទីដដែល។

តាមរបាយការណ៍ នៅដើមខែកុម្ភៈ និងនៅចុងខែមេសា មានការប៉ះទង្គិចគ្នា និងការបាញ់កាំភ្លើងធំទៅវិញទៅមក រវាងកងកម្លាំងសន្តិសុខកម្ពុជា និងថៃ នៅតំបន់ប្រាសាទព្រះវិហារ/ជម្លោះព្រំដែន ដែលនាំឱ្យមានរបាយការណ៍គ្មានការអះអាងថា មានជនស៊ីវិលថៃម្នាក់ត្រូវបានសម្លាប់ ភូមិករកម្ពុជា និងថៃរាប់ពាន់នាក់ ត្រូវភៀសសឹកជាបណ្តោះអាសន្ន ចំណែកឯទ្រព្យសម្បត្តិជនស៊ីវិលក៏ត្រូវទទួលរងនូវខូចខាតផងដែរ។

## ខ. ការបាត់ខ្លួន

គ្មានរបាយការណ៍ស្តីពីការបាត់ខ្លួនដោយសារមូលហេតុនយោបាយឡើយ។

## គ. ទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក

រដ្ឋធម្មនុញ្ញហាមឃាត់ចំពោះអំពើដូចពោលទាំងនេះ ទោះជាយ៉ាងណាក៏ដោយ ការវាយដំ និងការប្រព្រឹត្តលើរូបរាងកាយមិនត្រឹមត្រូវជាទម្រង់ផ្សេងៗទៀតចំពោះអ្នកជាប់ឃុំក្នុងប៉ុស្តិ៍នគរបាល និងអ្នកជាប់ពន្ធនាគារនៅតែមានជាបន្ត ចំណែកឯចំនួនឧប្បត្តិហេតុ ត្រូវបានរាយការណ៍ថា មានការកើនឡើងជាងឆ្នាំ២០១០។

មានរបាយការណ៍ដែលអាចជឿទុកចិត្តបានថា មន្ត្រីកងរាជអាវុធហត្ថ និងនគរបាលស៊ីវិល បានប្រើប្រាស់ទារុណកម្មផ្លូវកាយ និងផ្លូវចិត្ត ហើយនៅពេលខ្លះ បានវាយដំយ៉ាងធ្ងន់ធ្ងរលើអ្នកជាប់ឃុំករណីព្រហ្មទណ្ឌ ជាពិសេសនៅអំឡុងពេលសួរចម្លើយ។ គិតមកត្រឹមខែវិច្ឆិកា អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា អាជ្ញាធរបានធ្វើទារុណកម្មអ្នកទោស យ៉ាងហោចណាស់ចំនួន ១២៩នាក់ រួមមានអ្នកជាប់ឃុំក្នុងប៉ុស្តិ៍នគរបាលចំនួន ១២៤នាក់ និងអ្នកជាប់ពន្ធនាគារចំនួន ៥នាក់។ មានការរាយការណ៍អំពីបែបផែនរំលោភបំពានផ្នែករាងកាយដែលតែងតែកើតមានឡើងញឹកញាប់ដូចជា ការទាត់ធាក់ ការដាល់ និងការវាយនឹងកាំភ្លើងខ្លី ប៉ុន្តែ ក៏មានការប្រើប្រាស់ការឆក់ខ្សែភ្លើង ការធ្វើឱ្យថប់ដង្ហើម ការចាប់ជ្រមុជក្នុងធុងទឹក និងការវាយនឹងខ្សែភ្លើង។ អង្គការ មិនមែនរដ្ឋាភិបាលបានរាយការណ៍ថា នេះមិនមែនជារឿងចម្លែកឡើយ ចំពោះនគរបាលដែលធ្វើទារុណកម្មលើជន

សង្ស័យជាប់ឃុំឃាំង រហូតទាល់តែពួកគេសារភាពចំពោះបទល្មើសព្រហ្មទណ្ឌ។ តុលាការបានប្រើប្រាស់ការសារភាពដោយបង្ខំ ទុកជាភ័ស្តុតាងស្របច្បាប់ នៅអំឡុងពេលជម្រះក្តី ទោះបីជាការសារភាពបែបនេះ ត្រូវបានហាមឃាត់ដោយច្បាប់ក៏ដោយ។

នៅថ្ងៃទី២៤ ខែមីនា មន្រ្តីនគរបាល ២នាក់ នៅខេត្តព្រះសីហនុ ត្រូវបានចោទប្រកាន់ថា បានវាយដំលើជនសង្ស័យម្នាក់ ដើម្បីបង្ខំឱ្យគាត់សារភាពអំពីការជាប់ពាក់ព័ន្ធរបស់គាត់នៅក្នុងជម្លោះគ្នាតាមដងផ្លូវមួយ។ ជនសង្ស័យដែលត្រូវរងរបួសយ៉ាងធ្ងន់ធ្ងរដោយសារការវាយដំនោះ បានដាក់ពាក្យបណ្តឹងទៅកាន់តុលាការខេត្ត។ គិតមកត្រឹមខែវិច្ឆិកា សំណុំរឿងនេះ នៅរង់ចាំការកំណត់កាលបរិច្ឆេទជំនុំជម្រះក្តីនៅឡើយ។

នៅខែមិថុនា ដោយបញ្ជាក់ថា ដោយសារគ្មានភ័ស្តុតាងគ្រប់គ្រាន់ តុលាការខេត្ត ក៏លើកការចោទប្រកាន់លើករណីបណ្តឹងប្រឆាំងនឹងមន្រ្តីនគរបាល នៅឃុំត្នោតជុំ កាលពីខែឧសភា ឆ្នាំ២០១០ ដែលបានវាយដំ និងឆក់ខ្សែភ្លើង ដើម្បីទទួលបានការសារភាពនៅក្នុងករណីឈ្លោះគ្នាតាមដងផ្លូវមួយ។ ជនរងគ្រោះនោះ បានដាក់ពាក្យបណ្តឹងទៅកាន់តុលាការខេត្ត ដែលបានចោទប្រកាន់មន្រ្តីនគរបាលនោះពីបទបំពានលើរាងកាយ។

គិតមកត្រឹមខែតុលា អង្គការសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា (អាដហុក) ដែលជាអង្គការមិនមែនរដ្ឋាភិបាល បានរាយការណ៍ថា ករណីនៃការប្រើប្រាស់កម្លាំងប្រឆាំងនឹងជនស៊ីវិលចំនួន ១០៨ករណី ដោយអាជ្ញាធរដែនដី ភ្នាក់ងាររដ្ឋាភិបាល ឬអង្គរក្សឯកជនរបស់មន្រ្តីរដ្ឋាភិបាលនៅអំឡុងឆ្នាំនេះ បើប្រៀបធៀបនឹង ៨៦ករណីនៅឆ្នាំ២០១០។ នៅក្នុងករណីជាក់ស្តែងមួយចំនួន នគរបាលបានប្រើប្រាស់កម្លាំងប្រឆាំងនឹងការគំរាមកំហែងប្រើអំពើហិង្សា ឬប្រព្រឹត្តអំពើហិង្សាលើបាតុករ។ ក្នុងករណីខ្លះទៀត នគរបាលបានប្រើប្រាស់កម្លាំងប្រឆាំងនឹងបាតុករដោយសន្តិវិធី ក្រោយពីបាតុកររំខានដល់ចរាចរណ៍ និងបដិសេធមិនបំបែកបាតុកម្មតាមបញ្ជា។

មានមជ្ឈមណ្ឌលស្តារនីតិសម្បទាគ្រឿងញៀនដែលដំណើរការដោយរដ្ឋាភិបាលចំនួន ១១កន្លែង។ អ្នកសង្កេតការណ៍ភាគច្រើនបំផុតបានយល់ស្របគ្នាថា អ្នកជាប់ឃុំភាគច្រើន នៅក្នុងមណ្ឌលទាំងនោះ ត្រូវបានយកទៅដាក់នៅទីនោះដោយបង្ខំ ដោយអាជ្ញាធរអនុវត្តច្បាប់ ឬសមាជិកគ្រួសារ ហើយអ្នកជាប់ឃុំចំនួន ១ ភាគ ៣ មានអាយុក្រោម ១៨ឆ្នាំ។ និយោជិតធ្វើការនៅមណ្ឌលទាំងនោះ ជារឿយៗ បានគ្រប់គ្រងអ្នកជាប់ឃុំទាំងនោះដោយចង ឬឱ្យធ្វើលំហាត់ប្រាណខ្លាំង និងឆក់ខ្សែភ្លើង។ ថ្នាក់ដឹកនាំរដ្ឋាភិបាល បានទទួលស្គាល់អំពីសារៈសំខាន់នៃការព្យាបាលភាពញៀនគ្រឿងញៀន ទុកជាបញ្ហាសុខភាព ជាជាងបញ្ហាព្រហ្មទណ្ឌ ប៉ុន្តែ មានការអនុវត្តបន្តិចបន្តួចទៅលើការថ្លែងដូច្នេះ។

## ស្ថានភាពពន្ធនាគារ និងមណ្ឌលឃុំខ្លួន

ស្ថានភាពពន្ធនាគារ ពុំបានបំពេញតាមស្តង់ដារអន្តរជាតិឡើយ។ ស្ថានភាពនៅមានសភាពឃោរឃៅ ហើយមានពេលខ្លះមានលក្ខណៈគំរាមកំហែងដល់អាយុជីវិតទៀតផង។ អង្គការសិទ្ធិមនុស្សនានា បានលើក ឡើងអំពីបញ្ហាធ្ងន់ធ្ងរ រួមមានដូចជាការមានអ្នកទោសយ៉ាងច្រើនខ្លាំង បញ្ហាសុខភាព និងអនាម័យ កង្វះចំណីអាហារ និងទឹក កង្វះអាហារូបត្ថម្ភ និងសន្តិសុខមិនល្អជាដើម។ នាយកដ្ឋានពន្ធនាគារ បានរាយការណ៍ថា មានអ្នកជាប់ពន្ធនាគារចំនួន ៣២នាក់ បានស្លាប់នៅអំឡុងពេលជាប់ឃុំ គិតមកត្រឹមខែកញ្ញា។ នគរបាលបាន អះអាងថា ខ្លួនបានធ្វើការស៊ើបអង្កេតអំពីករណីស្លាប់ទាំងនេះ និងបានរកឃើញថា ពួកគេបានស្លាប់ ដោយសារស្ថានភាពដែលកើតមាន

មុនពេលជាប់ពន្ធនាគារ ឬដោយសារជំងឺផ្សេងៗ។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ បានបញ្ជាក់ថា ប្រាក់ឧបត្ថម្ភសម្រាប់ចំណីអាហារ របស់របរប្រើប្រាស់ដែលចាំបាច់សម្រាប់អ្នកជាប់ពន្ធនាគារមានមិនគ្រប់គ្រាន់ឡើយ។ អ្នកសង្កេតការណ៍បានបន្តរាយការណ៍ថា ប្រាក់ឧបត្ថម្ភសម្រាប់ទិញចំណីអាហារសម្រាប់អ្នកជាប់ពន្ធនាគារជួនកាលមានលក្ខណៈមិនសមស្រប ដែលរឹតតែធ្វើឱ្យកង្វះខាតអាហារូបត្ថម្ភ និងជំងឺកាន់តែមានសភាពធ្ងន់ធ្ងរ។

យោងតាមនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ គិតមកត្រឹមខែកញ្ញា មានអ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំចំនួន១៥.៣៦១នាក់ នៅក្នុងប្រទេសកម្ពុជា រួមមានស្ត្រីចំនួន ១.២៤០នាក់ និងអនីតិជនចំនួន ៩៥១នាក់។ មានពន្ធនាគារចំនួន ២៧ នៅទូទាំងប្រទេស ដែលត្រូវបានរៀបចំឡើងដើម្បីដាក់មនុស្សចំនួន ១១.០០០នាក់។ មានរបាយការណ៍ថា នៅពន្ធនាគារមួយចំនួន មានបន្ទប់ដែលមានទំហំ ៤០ x ២០ ហ្វីត ដែលដាក់អ្នកទោសចំនួន ១១០នាក់។

នៅក្នុងពន្ធនាគារភាគច្រើន គ្មានការបំបែកអ្នកទោសជាមនុស្សពេញវ័យចេញពីអ្នកទោសជាអនីតិជន ពីបុរសចេញពីស្ត្រី ឬពីអ្នកមានទោសឧក្រិដ្ឋធ្ងន់ធ្ងរចេញពីអ្នកជាប់ឃុំសម្រាប់បទល្មើសស្រាលឡើយ។ ជាទម្លាប់ អ្នកជាប់ឃុំមុនពេលជម្រះក្តី ត្រូវបានដាក់ជាមួយគ្នានឹងអ្នកទោសដែលប្រកាសសាលក្រមរួចហើយ។ យោងតាមស្ថិតិរដ្ឋាភិបាល មានអ្នកជាប់ពន្ធនាគារប្រមាណជា ២៨ភាគរយ ដែលត្រូវបានដាក់នៅក្នុងពន្ធនាគាររាជធានី និងខេត្ត គឺជាអ្នកជាប់ឃុំមុនពេលជម្រះក្តី គិតមកត្រឹមខែកញ្ញា។

ជាទម្លាប់ អ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំត្រូវបានអនុញ្ញាតឱ្យជួបអ្នកមកសួរសុខទុក្ខ ទោះជាយ៉ាងណាក៏ដោយ អង្គការសិទ្ធិមនុស្សនានា បានអះអាងថា ក្រុមគ្រួសារ ជួនកាលបានធ្វើការសូកប៉ាន់ដល់មន្ត្រីពន្ធនាគារ ដើម្បីបានសាកសួរសុខទុក្ខអ្នកជាប់ពន្ធនាគារ ឬដើម្បីផ្តល់ចំណីអាហារ និងរបស់របរចាំបាច់ដទៃទៀត។ អង្គការមិនមែនរដ្ឋាភិបាល ក៏បានភ្ជាប់ដំណើររឿងថា អ្នកជាប់ពន្ធនាគារ ដែលក្រុមគ្រួសាររបស់ខ្លួនបានសូកប៉ាន់អាជ្ញាធរពន្ធនាគារទទួលបានការអនុគ្រោះ រួមមានលទ្ធភាពជួបអ្នកមកសួរសុខទុក្ខ ការផ្ទេរទៅរកបន្ទប់ល្អប្រសើរជាងមុន និងឱកាសចាកចេញពីបន្ទប់នៅអំឡុងពេលថ្ងៃជាដើម។ ទោះបីជាមានការប្រើប្រាស់មធ្យោបាយជំនួសឱ្យការដាក់ពន្ធនាគារកាន់តែប្រសើរឡើង អាចជួយកាត់បន្ថយចំនួនអ្នកជាប់ឃុំ និងការដាក់ទោសប្រជាជនក៏ដោយ ក៏នៅមានវឌ្ឍនភាពបន្តិចបន្តួចប៉ុណ្ណោះ ក្នុងការប្រើប្រាស់មធ្យោបាយជំនួសទាំងនោះ។ ការធានាឱ្យនៅក្រៅឃុំ មិនត្រូវបានប្រើប្រាស់ឱ្យដល់កម្រិតទេ ចំណែកឯ ប្រព័ន្ធដោះលែងដែលត្រូវបានអនុញ្ញាតនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ មិនទាន់ត្រូវបានអនុវត្តនៅឡើយទេ មកដល់ដំណាច់ឆ្នាំនេះ។ តំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយរូប បានធ្វើការកត់សម្គាល់ថា រដ្ឋាភិបាលខ្វះសមត្ថភាពដែលត្រូវការជាមុន ដើម្បីអនុវត្តកម្មវិធីដែលបានលើកឡើងទាំងនេះ។

មានរបាយការណ៍ដែលគួរឱ្យជឿទុកចិត្តបានថា ជួនកាលមន្ត្រីបានទាមទារសំណូកមុននឹងអនុញ្ញាតឱ្យអ្នកជាប់ពន្ធនាគារទៅចូលជម្រះក្តី ឬសវនាការឧទ្ធរណ៍ និងមុនពេលដោះលែងអ្នកជាប់ពន្ធនាគារ ដែលបានបញ្ចប់តាមរយៈពេលជាប់ទោសក្នុងពន្ធនាគាររួចហើយ។

អ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំ ត្រូវបានអនុញ្ញាតឱ្យគោរពសាសនារបស់ខ្លួនផ្ទាល់។ បណ្តឹងអំពីការរំលោភបំពានដែលត្រូវបានចោទប្រកាន់ អាចដាក់ទៅកាន់អាជ្ញាធរតុលាការ តាមរយៈមេធាវី ដោយគ្មានការត្រួតពិនិត្យ ទោះជាយ៉ាងណាក៏ដោយ អ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំមួយចំនួនធំ គ្មានលទ្ធភាពស្វែងរកតំណាងផ្នែក

ច្បាប់បានឡើយ។ រដ្ឋាភិបាលបានធ្វើការស៊ើបអង្កេតបណ្តឹងទាំងនោះ និងត្រួតពិនិត្យស្ថានភាពពន្ធនាគារ និងមណ្ឌលឃុំខ្លួន តាមរយៈនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ ដែលរៀបចំរបាយការណ៍ ២ដងក្នុងឆ្នាំ អំពីការគ្រប់គ្រង និងការកែលម្អពន្ធនាគារនៅក្នុងប្រទេស។ របាយការណ៍ទាំង នេះ ក៏ដូចជារបាយការណ៍ស៊ើបអង្កេតដទៃទៀត អាចផ្តល់ជូនសាធារជន តាមការស្នើសុំ។

ជាទូទៅ រដ្ឋាភិបាល បន្តអនុញ្ញាតឱ្យក្រុមអង្គការសិទ្ធិមនុស្សអន្តរជាតិ និងក្នុងស្រុក រួមមានដូចជាគណៈកម្មការកាកបាទក្រហមអន្តរជាតិ និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ជាដើម ចូលទស្សនកិច្ចពន្ធនាគារ និងផ្តល់ការបណ្តុះបណ្តាលអំពីសិទ្ធិមនុស្សដល់ឆ្មាំ ពន្ធនាគារ។ មានអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានរាយការណ៍ថា នៅពេលខ្លះ កិច្ចសហប្រតិបត្តិការ ពីអជ្ញាធរមូលដ្ឋាន នៅមានកម្រិត ធ្វើឱ្យមានការលំបាកដើម្បីចូលជួបអ្នកជាប់ឃុំមុនពេលជម្រះក្តី។ ក្រសួង មហាផ្ទៃតម្រូវឱ្យមេធាវី អ្នកឃ្លាំមើលសិទ្ធិមនុស្ស និងអ្នកមកសួរសុខទុក្ខ សុំការអនុញ្ញាតជាមុន មុននឹង ចូលសួរសុខទុក្ខអ្នកជាប់ពន្ធនាគារ។ ខុសពីឆ្នាំកន្លងទៅ គ្មានករណីដែលអាជ្ញាធរបដិសេធមិនផ្តល់ការ អនុញ្ញាត ដូចពោលនេះទេ។ ក្នុងករណីខ្លះ មន្ត្រីបានអនុញ្ញាតឱ្យអង្គការមិនមែនរដ្ឋាភិបាលធ្វើការសម្ភាសន៍អ្នកជាប់ ពន្ធនាគារជាលក្ខណៈឯកជន។ តំណាងការិយាល័យឧត្តមស្នងការអង្គការសហប្រជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានរាយការណ៍ថា តាមធម្មតា ពួកគេអាចជួបជាលក្ខណៈឯកជន នៅពេលសម្ភាសន៍អ្នកជាប់ពន្ធនាគារណា ម្នាក់ដែលពាក់ព័ន្ធបាន។

### ឃ. ការចាប់ខ្លួន ឬការឃុំខ្លួនដោយរំលោភបំពាន

ច្បាប់ចែងហាមឃាត់ចំពោះការចាប់ខ្លួន និងការឃុំខ្លួនដោយរំលោភបំពាន ទោះជាយ៉ាងណាក៏ដោយ នៅពេលខ្លះ រដ្ឋាភិបាលពុំបានគោរពបម្រាមទាំងនេះទេ។

### តួនាទីរបស់នគរបាល និងយន្តការសន្តិសុខ

អគ្គស្នងការនគរបាលជាតិ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ ជាអ្នកគ្រប់គ្រងអង្គភាពនគរបាលស៊ីវិលទាំងអស់។ កម្លាំងនគរបាល ត្រូវបានបែងចែកជាកម្លាំងនគរបាលដែលមានអំណាចធ្វើការចាប់ខ្លួន ជាកម្លាំងដែលគ្មានអំណាចចាប់ខ្លួន និងនគរបាលយុត្តិធម៌។ កងរាជអាវុធហត្ថ ត្រូវបានអនុញ្ញាតឱ្យធ្វើការចាប់ខ្លួនជនស៊ីវិលបាន ក្នុងករណីមន្ត្រីទាំងនោះ បានបំពេញលក្ខខណ្ឌបណ្តុះបណ្តាល និងមានបទពិសោធន៍បំពេញតួនាទីជានគរបាលយុត្តិធម៌បាន ប្រសិនបើជនស៊ីវិលស្ថិតនៅក្នុងដែនដីរបស់យោធា ឬប្រសិនបើត្រូវបានអនុញ្ញាតដោយរដ្ឋាភិបាលមូលដ្ឋាន។ ទោះជាយ៉ាងណាក៏ដោយ ក្នុងការអនុវត្តជាក់ស្តែង កងរាជអាវុធហត្ថជួនកាល បានចូលរួមក្នុងសកម្មភាពអនុវត្តច្បាប់ចំពោះជនស៊ីវិល ដែលជាធម្មតាស្ថិតនៅក្រោមអំណាច និងការដឹកនាំរបស់អាជ្ញាធរខេត្ត ឬអាជ្ញាធរមូលដ្ឋាន ហើយជារឿយៗ ដើម្បីគាំទ្រដល់នគរបាលស៊ីវិលដែលមិនអាចមានលទ្ធភាពគ្រប់គ្រងហ្វូងមនុស្សប្រកបដោយប្រសិទ្ធភាពដោយខ្លួនឯង។

អង្គការមិនមែនរដ្ឋាភិបាលនានា បានអះអាងថា មន្ត្រីនគរបាលបានប្រព្រឹត្តការរំលោភបំពានដោយគ្មានទោសពៃរ៍ ហើយនៅក្នុងករណីជាច្រើនបំផុត រដ្ឋាភិបាលបានចាត់វិធានការបន្តិចបន្តួច ឬមិនចាត់វិធានការសោះតែម្តង។ ច្បាប់តម្រូវឱ្យនគរបាល ព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេត គ្រប់បណ្តឹងទាំងអស់ រួមទាំងបណ្តឹងអំពីការរំលោភបំពានរបស់នគរបាលផងដែរ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តជាក់ស្តែង ចៅក្រម និង

ព្រះរាជអាជ្ញា កម្រនឹងធ្វើការសង្កេតដោយឯករាជ្យដែលជាផ្នែកមួយនៃការជំនុំជម្រះក្តីជាសាធារណៈណាស់។ ប្រធានអង្គជំនុំជម្រះ តែងតែចេញសាលក្រម ផ្អែកតាមរបាយការណ៍ជាលាយលក្ខណ៍អក្សរពីនគរបាល និងសក្ខីកម្មរបស់សាក្សី។ ជាទូទៅ នគរបាលទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈបន្តិចបន្តួចប៉ុណ្ណោះ។

## នីតិវិធីចាប់ខ្លួន និងការប្រព្រឹត្តនៅពេលឃុំខ្លួន

ច្បាប់តម្រូវឱ្យនគរបាលមានដីកាពីចៅក្រមស៊ើបអង្កេតមុននឹងធ្វើការចាប់ខ្លួន ប៉ុន្តែ នគរបាលអាចធ្វើការចាប់ខ្លួនដោយពុំចាំបាច់មានដីកាទេ ប្រសិនមានជនណាម្នាក់ត្រូវបានតាមទាន់ នៅពេលកំពុងប្រព្រឹត្តបទឧក្រិដ្ឋណាមួយ។ ច្បាប់អនុញ្ញាតឱ្យនគរបាលឃុំខ្លួនជនណាម្នាក់ និងធ្វើការស៊ើបអង្កេតក្នុងរយៈពេល ៤៨ម៉ោង ដោយមិនរាប់បញ្ចូលរយៈពេលចុងសប្តាហ៍ និងថ្ងៃឈប់សម្រាករបស់រដ្ឋាភិបាលឡើយ មុននឹងត្រូវធ្វើការចោទប្រកាន់។ នៅក្នុងករណីបទឧក្រិដ្ឋចំពោះស្ថានភាពលើកលែងដែលកំណត់ដោយច្បាប់ នគរបាលអាចធ្វើការឃុំខ្លួនជនសង្ស័យរយៈពេល ២៤ម៉ោងបន្ថែមទៀត ដោយមានការយល់ព្រមពីព្រះរាជអាជ្ញា។ ប៉ុន្តែ ជាទម្លាប់ អាជ្ញាធរឃុំខ្លួនមនុស្សរយៈពេលយូរ មុននឹងធ្វើការចោទប្រកាន់។ មានប្រព័ន្ធធានាឱ្យនៅក្រៅឃុំដែលមានដំណើរការមួយ ប៉ុន្តែ មានអ្នកជាប់ពន្ធនាគារជាច្រើន ជាពិសេស អ្នកដែលគ្មានតំណាងផ្នែកច្បាប់ ពុំមានឱកាសដើម្បីស្វែងរកការធានាដោះលែងឱ្យនៅក្រៅឃុំឡើយ។ តាមក្រមនីតិវិធីព្រហ្មទណ្ឌ ជនជាប់ចោទអាចត្រូវចាប់ខ្លួន និងឃុំខ្លួន រយៈពេលដល់ទៅ ២៤ម៉ោង មុននឹងទទួលបានការប្រឹក្សាយោបល់ផ្នែកច្បាប់ ប៉ុន្តែ អ្នកជាប់ពន្ធនាគារ ជាទម្លាប់ ត្រូវបានឃុំខ្លួន ដោយគ្មានការប្រាស្រ័យទាក់ទងរយៈពេលជាច្រើនថ្ងៃ មុននឹងទទួលបានមេធាវី ឬជួបសមាជិកគ្រួសារ។ យោងតាមមន្ត្រីរដ្ឋាភិបាល ការឃុំខ្លួនរយៈពេលយូរនេះ ភាគច្រើន បណ្តាលមកពីសមត្ថភាពមានកម្រិតរបស់ប្រព័ន្ធតុលាការ។

<u>ការចាប់ខ្លួនដោយរំលោភបំពាន៖</u> អង្គការអាដហុកបានរាយការណ៍ថា យ៉ាងហោចណាស់ មានការចាប់ខ្លួន ឬការឃុំខ្លួន ចំនួន ៦៨ករណី ដែលអង្គការនេះចាត់ទុកថា មានលក្ខណៈរំលោភបំពាន គិតមកត្រឹមខែតុលា ប៉ុន្តែ ពុំបានផ្តល់ឧទាហរណ៍ជាក់ស្តែងឡើយ។ អង្គការអាដហុកបានបញ្ជាក់ថា មានជនរងគ្រោះស្ថិតក្នុងករណីឃុំខ្លួនដោយរំលោភបំពានចំនួន ២៥នាក់ ត្រូវបានដោះលែងឱ្យមានសេរីភាពនៅពេលបន្ទាប់មក ក្រោយពីមានបណ្តឹងពីជនជាប់ឃុំ ការអន្តរាគមន៍របស់អង្គការមិនមែនរដ្ឋាភិបាលដែលជាអង្គការសិទ្ធិមនុស្ស ឬការបង់ប្រាក់សំណូក។ អង្គការហាដហុកមានជំនឿថា ចំនួនជាក់ស្តែងនៃការចាប់ខ្លួន និងការឃុំខ្លួនដោយបំពានមានច្រើនជាងនេះ ពីព្រោះជនរងគ្រោះមួយចំនួននៅតាមតំបន់ជនបទមិនបានដាក់ពាក្យបណ្តឹង ដោយសារមានការលំបាកក្នុងការធ្វើដំណើរមកកាន់ការិយាល័យអង្គការអាដហុក ឬដោយសារមានការព្រួយបារម្ភអំពីបញ្ហាសន្តិសុខក្រុមគ្រួសាររបស់ខ្លួន។ យោងតាម អង្គការអាដហុក អាជ្ញាធរពុំបានចាត់វិធានការផ្លូវច្បាប់ ឬវិធានការវិន័យចំពោះជនដែលទទួលខុសត្រូវចំពោះការឃុំខ្លួនខុសច្បាប់ឡើយ។

នៅអំឡុងឆ្នាំនេះ អាជ្ញាធររាជធានីភ្នំពេញបានចាប់ខ្លួនមនុស្សរាប់សិបនាក់ ជាទូទៅ គឺជាអ្នកគ្មានផ្ទះសម្បែង អ្នកមានជំងឺផ្លូវចិត្ត អ្នកប្រើប្រាស់គ្រឿងញៀន ឬអ្នកបំរើសេវាផ្លូវភេទ នៅអំឡុងពេលបោសសម្អាតដងផ្លូវជាលក្ខណៈប្រព័ន្ធ។ ជាទូទៅ អ្នកជាប់ឃុំបានបាត់បង់ប្រាក់កាស និងកម្មសិទ្ធិទាំងអស់នៅក្នុងពេលបោសសម្អាត។ អាជ្ញាធរបានហៅការបោសសម្អាតដងផ្លូវនោះថា ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងដើម្បី "ធ្វើឱ្យសង្គមមានសណ្តាប់ធ្នាប់"។ មានពេលខ្លះ អាជ្ញាធរបានដាក់អ្នកជាប់ឃុំនៅមជ្ឈមណ្ឌលស្តារនីតិសម្បទាដែលដំណើរការដោយក្រសួង

សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MOSAVY) ដែលមានចម្ងាយ ១៥ម៉ាយល៍ពីក្រុងភ្នំពេញ។ អ្នកជាប់ឃុំត្រូវបានគេប្រាប់ថា ពួកគេអាចចាកចេញបាន ប៉ុន្តែ នឹងមិនបានទទួលមធ្យោបាយធ្វើដំណើរទេ។

<u>ការឃុំខ្លួនមុនពេលជម្រះក្តី៖</u> ក្រមនីតិវិធីព្រហ្មទណ្ឌ អនុញ្ញាតឱ្យមានការឃុំខ្លួនមុនពេលជម្រះក្តីរហូតដល់ទៅរយៈពេល ៦ខែ សម្រាប់បទល្មើសមជ្ឈិម និងរយៈពេល ១៨ខែសម្រាប់បទឧក្រិដ្ឋ។ អ្នកជាប់ឃុំម្នាក់ក្នុងចំណោមអ្នកជាប់ឃុំ១៧នាក់ មុនពេលជម្រះក្តី ត្រូវបានដាក់ឃុំលើសរយៈពេលដែលច្បាប់កំណត់ ជួនកាលគ្មានតំណាងផ្នែកច្បាប់ឡើយ។ គិតមកត្រឹមខែកញ្ញា ក្រសួងមហាផ្ទៃ បានរាយការណ៍ថា មានមនុស្សចំនួន ២៤៦នាក់ ស្ថិតនៅក្នុងការឃុំខ្លួនមុនពេលជម្រះក្តី លើសរយៈពេលច្បាប់បានកំណត់សម្រាប់បទល្មើសដែលបានចោទប្រកាន់។ ជាងនេះទៅទៀត តុលាការមួយចំនួនបានបាត់ឯកសារបណ្តឹងនៅអំឡុងរយៈពេលឃុំខ្លួនមុនពេលជម្រះក្តី ធ្វើឱ្យមានការយឺតយ៉ាវដល់នីតិវិធីតុលាការ។

<u>ការលើកលែងទោស៖</u> ព្រះមហាក្សត្រអាចលើកលែងទោសក្នុងករណីមួយចំនួន ដែលព្រះអង្គតែងធ្វើឡើងនៅអំឡុងពេលពិធីបុណ្យព្រះពុទ្ធសាសនាសំខាន់ៗ និងថ្ងៃបុណ្យជាតិ។ ក្រសួងមហាផ្ទៃបានរាយការណ៍ថា ព្រះបាទនរោត្តមសីហមុនី បានលើកលែងទោសមនុស្សចំនួន ៦៨នាក់ គិតមកត្រឹមខែកញ្ញា។

### ង. ការបដិសេធការជំនុំជម្រះក្តីជាសាធារណៈដោយយុត្តិធម៌

រដ្ឋធម្មនុញ្ញបានផ្តល់ឱ្យមានតុលាការឯករាជ្យ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង រដ្ឋាភិបាល ជាទូទៅ មិនបានគោរពឯករាជ្យភាពរបស់តុលាការឡើយ។ តុលាការស្ថិតក្រោមឥទ្ធិពល និងការជ្រៀតជ្រែកពីអង្គនីតិបញ្ញត្តិ និងមានអំពើពុករលួយរីករាលដាលនៅក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការ។

កង្វះខាតធនធាន ប្រាក់បៀវត្សរ៍ទាប និងការបណ្តុះបណ្តាលមិនបានល្អ រួមចំណែកធ្វើឱ្យមានអំពើពុករលួយកម្រិតខ្ពស់ និងអប្រសិទ្ធភាពក្នុងតុលាការ ចំណែកឯរដ្ឋាភិបាល មិនបានផ្តល់ដំណើរការត្រឹមត្រូវឡើយ។

អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា មានករណីជាច្រើនរង់ចាំការចាត់ការ ដោយសារខ្វះចៅក្រម និងបន្ទប់សវនាការ។ អង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ ក៏បានប្រមើលថា មន្ត្រីតុលាការផ្តោតតែទៅលើករណីដែលពួកគាត់អាចទទួលបានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុប៉ុណ្ណោះ។

ក្នុងករណីពាក់ព័ន្ធនឹងបុគ្គលិកយោធាវិញ ជារឿយៗ មន្ត្រីយោធា បានដាក់សម្ពាធលើចៅក្រមរបស់តុលាការព្រហ្មទណ្ឌស៊ីវិល ដើម្បីឱ្យដោះលែងចុងចោទដោយពុំចាំបាច់មានការជំនុំជម្រះក្តី។
ការយឺតយ៉ាវ ឬអំពើពុករលួយរបស់តុលាការ ជារឿយៗ បានបណ្តោយឱ្យជនជាប់ចោទ រួចផុតពីការកាត់ទោស។ មន្ត្រីរដ្ឋាភិបាល ឬសមាជិកគ្រួសាររបស់ពួកគេ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ជារឿយៗ មិនទទួលបានការដាក់ទោសពៃរ៍អ្វីឡើយ។

អង្គការមិនមែនរដ្ឋាភិបាលបានអះអាងថា ក្នុងករណីព្រហ្មទណ្ឌជាច្រើន ចុងចោទជាអ្នកមានទ្រព្យសម្បត្តិ និងមានអំណាច រួមមានដូចជាសមាជិកកងកម្លាំងសន្តិសុខ ជាដើម បានបង់ប្រាក់ទៅឱ្យជនរងគ្រោះ និងអាជ្ញាធរ ឱ្យ

បោះបង់បណ្ដឹងព្រហ្មទណ្ឌ។ គេបានដឹងថា អាជ្ញាធរ បានបង្ខំឱ្យជនរងគ្រោះ ឬក្រុមគ្រួសាររបស់ពួកគេឱ្យទទួលយកសំណងជាប្រាក់ជាថ្នូរនឹងការបោះបង់បណ្ដឹងព្រហ្មទណ្ឌ ឬមិនបានមកបង្ហាញខ្លួនជាសាក្សី។

មរណភាពនៅខែមករា ឆ្នាំ២០១០ របស់ឈ្មោះ លន់ ឈុនឡេង គឺជាឧទាហរណ៍មួយនៃអប្រសិទ្ធភាពរបស់តុលាការ។ អង្គការសិទ្ធិមនុស្សក្នុងស្រុកមួយបានរាយការណ៍ថា ឈ្មោះ ជីល សារ៉ាត់ និង ស៊ុន វ៉ាន់ថា ជាមន្ត្រីនគរបាល ២នាក់ នៅខេត្តកណ្ដាល បានវាយប្រហារឈ្មោះ លន់ ឈុនឡេង ក្រោយពីមានការឈ្លោះប្រកែកគ្នានៅឯពិធីរៀបអាពាហ៍ពិពាហ៍មួយ។ ក្រោយមក ឈ្មោះ លន់ ឈុនឡេង បានស្លាប់ដោយសាររបួសរបស់គាត់ ចំណែកឯគ្រួសារជនរងគ្រោះបានដាក់ពាក្យបណ្ដឹងមួយទៅកាន់តុលាការខេត្ត។ មកដល់ដំណាច់ឆ្នាំនេះ កាលបរិច្ឆេទសវនាការពុំទាន់បានកំណត់នៅឡើយ ឯមន្ត្រីនគរបាល ២នាក់នោះ នៅតែមានសេរីភាពដដែល។

## នីតិវិធីជំនុំជម្រះក្ដី

ការជំនុំជម្រះក្ដីត្រូវធ្វើឡើងជាសាធារណៈ។ គណៈវិនិច្ឆ័យ មិនត្រូវបានប្រើប្រាស់ឡើយ ប្រធានអង្គជំនុំជម្រះមានអំណាចធ្វើការសម្រេចសាលក្រមបាន។ ចុងចោទ មានសិទ្ធិមានវត្តមាន និងពិគ្រោះយោបល់មេធាវី តទល់ និងសួរសំណួរសាក្សីប្រឆាំងនឹងខ្លួនបាន ព្រមទាំងអាចបង្ហាញសាក្សី និងភស្តុតាងដោយខ្លួនឯងបាន។ ក្នុងករណីព្រហ្មទណ្ឌ ប្រសិនបើចុងចោទមិនអាចរកមេធាវីបាន តុលាការត្រូវផ្ដល់តំណាងផ្នែកច្បាប់ដោយឥតគិតថ្លៃដល់ចុងចោទ ទោះជាយ៉ាងណាក៏ដោយ ជារឿយៗ តុលាការខ្វះខាតធនធានក្នុងការផ្ដល់យោបល់ផ្នែកច្បាប់ ហើយចុងចោទភាគច្រើនបំផុត បានស្វែងរកជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ឬចូលសវនាការដោយគ្មានតំណាងផ្នែកច្បាប់។ ជាតួយ៉ាង ការជំនុំជម្រះក្ដីធ្វើឡើងជាការគម្រប់កិច្ច ហើយ តាមធម្មតាមិនបានធ្វើការពិនិត្យពិច័យឱ្យហ្មត់ចត់ឡើយ។ ចុងចោទ និងមេធាវីរបស់ពួកគាត់មានសិទ្ធិពិនិត្យភស្តុតាងក្នុងដៃរបស់រដ្ឋាភិបាលដែលពាក់ព័ន្ធនឹងករណីរបស់ខ្លួនបាន ប៉ុន្តែ មានពេលខ្លះ ពួកគេមានការលំបាកនឹងទទួលសិទ្ធិបែបនេះ ជាពិសេស ប្រសិនបើករណីនោះ ពាក់ព័ន្ធនឹងរឿងនយោបាយ ឬទាក់ទងនឹងមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលដែលមានឋានៈខ្ពស់ ឬសមាជិកមានទំនាក់ទំនងល្អជាមួយអ្នកធំ។

នៅមានកង្វះខាតយ៉ាងធ្ងន់ធ្ងរនូវមេធាវីដែលបានទទួលការបណ្ដុះបណ្ដាលត្រឹមត្រូវ ជាពិសេស នៅតំបន់ក្រៅក្រុងភ្នំពេញ។ អ្នកគ្មានមធ្យោបាយស្វែងរកការប្រឹក្សាយោបល់ ជារឿយៗ ត្រូវបានគេបដិសេធពីការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌។ យោងតាមគណៈមេធាវី មានមេធាវីប្រមាណជា ៧៥១នាក់ ប្រមាណជា ៣០ ភាគរយនៅទូទាំងប្រទេសបានផ្ដល់ប្រឹក្សាផ្នែកច្បាប់ដោយឥតគិតថ្លៃដល់ជនក្រីក្រ ដែលចំនួននេះមិនគ្រប់គ្រាន់ដើម្បីផ្ដល់សិទ្ធិស្របច្បាប់ជាមូលដ្ឋានដល់ជនក្រីក្រទាំងអស់នៅក្នុងប្រទេសឡើយ។
ចុងចោទមានសិទ្ធិស្របច្បាប់ថា គ្មានទោសមុនពេលតុលាការចេញសាលក្រមសម្រេចទោស និងមានសិទ្ធិប្ដឹងឧទ្ធរណ៍ ប៉ុន្តែ ដោយសារអំពើពុករលួយដ៏រីករាលដាលនោះ ជារឿយៗ ចុងចោទ ត្រូវផ្ដល់សំណូកដល់ចៅក្រមដើម្បីទទួលបានសាលក្រមដែលមានលក្ខណៈអនុគ្រោះ។ អង្គការមិនមែនរដ្ឋាភិបាល ក៏បានរាយការណ៍ផងដែរថា សេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរដែលបានធ្វើសម្បថបានមកពីសាក្សី និងជនជាប់ចោទ តាមធម្មតាគ្រាន់តែជាភស្តុតាងដែលបានបង្ហាញនៅពេលជំនុំជម្រះប៉ុណ្ណោះ។ ជួនកាល សេចក្ដីថ្លែងការណ៍របស់ជនជាប់ចោទ ត្រូវធ្វើឡើងដោយបង្ខំ តាមរយៈការវាយដំ ឬការគំរាមកំហែង ហើយជារឿយៗ ចុងចោទដែលមិនចេះអក្សរមិនបានដឹងអំពីខ្លឹមសារនៃសេចក្ដីសារភាពជាលាយលក្ខណ៍អក្សរ ដែលខ្លួនត្រូវបានបង្ខំឱ្យចុះហត្ថលេខាឡើយ។ សិទ្ធិមានវត្តមាននៅក្នុងសវនាការឧទ្ធរណ៍របស់ប្រជាពលរដ្ឋ ជារឿយៗ ត្រូវបានកំហិតតាមរយៈបញ្ហាលំបាកក្នុង

ការផ្ទេរអ្នកទោសពីពន្ធនាគារខេត្តមកកាន់តុលាការឧទ្ធរណ៍នៅក្នុងក្រុងភ្នំពេញ។ ជាផលវិបាក សវនាការឧទ្ធរណ៍ជាងពាក់កណ្តាលនៃសវនាការឧទ្ធរណ៍ទាំងអស់ ត្រូវធ្វើឡើងដោយកំបាំងមុខ ចុងចោទ។

គ្មានការវិវឌ្ឍន៍ទាក់ទងនឹងការធ្វើឃាតកាលពីឆ្នាំ២០០៤ លើមេដឹកនាំកម្មករ-និយោជិត លោក ជា វិជ្ជា ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវគេបាញ់សម្លាប់នៅក្រុងភ្នំពេញឡើយ។ នៅក្នុងរយៈពេលមួយសប្តាហ៍ ជនសង្ស័យ ២នាក់ ឈ្មោះ ប៊ន សំណាង និង សុខ សំអឿន ត្រូវបានចាប់ខ្លួនដោយនគរបាល ហើយបន្ទាប់មក ត្រូវបានកាត់ទោសដាក់ពន្ធនាគាររយៈពេល ២០ឆ្នាំ ចំពោះតួនាទីរបស់ពួកគេនៅក្នុងបទឧក្រិដ្ឋនោះ។ ទោះជាយ៉ាងណាក៏ដោយ ករណីនេះត្រូវបានប្តឹងឧទ្ធរណ៍ទៅកាន់តុលាការកំពូល ដែលបានបដិសេធសេចក្តីសម្រេចរបស់តុលាការឧទ្ធរណ៍ រួចបានដោះលែង ប៊ន សំណាង និង សុខ សំអឿន ដោយ ការធានាឱ្យនៅក្រៅឃុំ។ បន្ទាប់មក ករណីនេះ ត្រូវបានបញ្ជូនត្រឡប់ទៅកាន់តុលាការឧទ្ធរណ៍វិញ ដែលមកដល់ដំណាច់ឆ្នាំនេះ មិនទាន់ចាត់ការនៅឡើយ។

**អ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំដោយសារនយោបាយ**

ពុំមានរបាយការណ៍អំពីអ្នកជាប់ពន្ធនាគារ ឬអ្នកជាប់ឃុំដោយសារនយោបាយទេ។

**នីតិវិធីតុលាការស៊ីវិល និងដំណោះស្រាយ**

ប្រទេសកម្ពុជាមានតុលាការមួយ ដើម្បីដោះស្រាយបញ្ហាស៊ីវិល ហើយប្រជាពលរដ្ឋ មានសិទ្ធិដាក់បណ្តឹងស្វែងរកសំណងខូចខាតសម្រាប់ការរំលោភសិទ្ធិមនុស្ស។ ជាទូទៅ មានទាំងដំណោះស្រាយរដ្ឋបាល និងដំណោះស្រាយតុលាការ។ ជារឿយៗ ការអនុវត្តដីការបង្គាប់របស់តុលាការសម្រាប់ករណីរដ្ឋប្បវេណី និងព្រហ្មទណ្ឌ គឺជាបញ្ហាមួយ។ ខុសពីឆ្នាំកន្លងៗទៅ ពុំមានរបាយការណ៍អំពីវិធានការអប្បមាទនៅអំឡុងឆ្នាំទេ។

**ច. ការជ្រៀតជ្រែកដោយរំលោភបំពានលើភាពឯកជន គ្រួសារ លំនៅឋាន ឬឯកសារទំនាក់ទំនង**

ច្បាប់មានចែងអំពីភាពឯកជននៃលំនៅឋាន និងឯកសារទំនាក់ទំនង ព្រមទាំងហាមឃាត់ចំពោះការឆែកឆេរដោយខុសច្បាប់ ប៉ុន្តែ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា ជាទម្លាប់ នគរបាលបានធ្វើការឆែកឆេរ និងរឹបអូសដោយគ្មានដីកា។

ការប្រមូលផ្តុំដោយបង្ខំ ក្រោមរបបខ្មែរក្រហម និងការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនភាគច្រើន បានបន្សល់ទុកឱ្យមានកម្មសិទ្ធិដីធ្លីមានលក្ខណៈមិនច្បាស់លាស់។ ច្បាប់ភូមិបាលចែងថា បុគ្គលណាដែលបានកាន់កាប់ដីឯកជន ឬឯកជនរបស់រដ្ឋ (មិនមែនជាដីសាធារណៈរបស់រដ្ឋ) ដោយសន្តិវិធី គ្មានការតវ៉ារយៈពេល ៥ឆ្នាំ មុនពេលប្រកាសឱ្យប្រើច្បាប់នេះនៅឆ្នាំ២០០១ មានសិទ្ធិស្នើសុំកម្មសិទ្ធិជាស្ថាពរលើដីនោះបាន។ ប្រជាជនក្រីក្រភាគច្រើនបំផុតនៅកម្ពុជា នៅតែបន្តខ្វះចំណេះដឹង និងមធ្យោបាយ ដើម្បីទទួលបានឯកសារផ្លូវការអំពីកម្មសិទ្ធិដី។

ការិយាល័យគ្រប់គ្រងដីធ្លីថ្នាក់ខេត្ត និងស្រុក នៅតែបន្តអនុវត្តនីតិវិធីចុះបញ្ជីដីមុនឆ្នាំ២០០១ ដែលមិនមានបញ្ចូលការវាស់វែងដីឱ្យបានត្រឹមត្រូវ និងការផ្តល់ឱកាសសម្រាប់ការផ្តល់យោបល់ជាសាធារណៈឡើយ។

គណៈកម្មការសុរិយោដីបានខកខានមិនបានធ្វើអត្តសញ្ញាណកម្ម និងបោះបង្គោលព្រំដីរបស់រដ្ឋ នាំឱ្យមានទំនាស់ និងការបណ្តេញចេញដែលជំរុញតាមរយៈវិធានការរបស់រដ្ឋ ដើម្បីអភិវឌ្ឍដីដែលមានទំនាស់។ ការប៉ាន់ប្រមាណតម្លៃដី បង្កឱ្យមានវិវាទនៅគ្រប់ខេត្តទាំងអស់ ហើយបង្កើនភាពតានតឹងរវាងសហគមន៍ជនបទក្រីក្រ និងឈ្មួញដីធ្លី។ សហគមន៍តាមក្រុង ប្រឈមមុខនឹងការបណ្តេញចេញដោយបង្ខំ ដោយសារគម្រោងអភិវឌ្ឍន៍ជាលក្ខណៈពាណិជ្ជកម្ម។

ករណីអ្នកភូមិត្រូវបានបង្ខំឱ្យផ្លាស់ប្តូរទីលំនៅ នៅតែមានជាបន្តបន្ទាប់ ចំនួនករណីដែលត្រូវបានរាយការណ៍ បានកើនឡើងពីឆ្នាំ២០១០។ មានបុគ្គលមួយចំនួនបានប្រើប្រាស់ការគំរាមកំហែងចាត់វិធានការផ្លូវច្បាប់ ឬការបណ្តេញចេញ ដើម្បីបំភិតបំភ័យជនក្រីក្រ និងជនងាយរងគ្រោះ ឱ្យដោះដូរដីនឹងសំណងដែលមានតម្លៃទាបជាងទីផ្សារ។ អង្គការអាដហុកបានរាយការណ៍ថា បានទទួលបណ្តឹងទាក់ទងនឹងដីចំនួន ២២០ករណីនៅអំឡុងឆ្នាំនេះ។ នៅអំឡុងពេលដូចគ្នានេះ មានអង្គការមិនមែនរដ្ឋាភិបាល មួយទៀតបានទទួលបណ្តឹងទាក់ទងនឹងដីចំនួន ៩៨ករណី នៅក្រុងភ្នំពេញ និងចំនួន ១៣ខេត្ត ប៉ះពាល់ប្រជាជនចំនួន ១១.៣៧៧គ្រួសារ។ ជារឿយៗ ជនក្រីក្រ ពុំមានឯកសារស្របច្បាប់ ដើម្បីគាំទ្រដល់ការទាមទារដីរបស់ខ្លួនឡើយ ហើយខ្វះជំនឿលើប្រព័ន្ធតុលាការ។ ប្រជាជនទាំងនោះមួយចំនួនត្រូវគេបណ្តេញចេញ តវ៉ាបានជោគជ័យនៅក្នុងចំណាត់ការរបស់តុលាការ ប៉ុន្តែភាគច្រើននៃបណ្តឹងនៅក្នុងតុលាការមិនទាន់បានសម្រេចនៅឡើយទេ។

នៅថ្ងៃទី២៩ ខែមេសា មន្រ្តីកងរាជអាវុធហត្ថប្រមាណជា ១០០នាក់ បានប្រឈមមុខនឹងអ្នកភូមិចំនួន ២.០០០នាក់ ដែលបានបិទផ្លូវជាតិលេខ៧៦ នៅស្រុកកែវសីមា ក្នុងខេត្តមណ្ឌលគិរី ដើម្បីតវ៉ានឹងការឆ្ការដីរបស់ខ្លួនរបស់លោក ម៉ុងរឹទ្ធី ដែលជាមាជិកព្រឹទ្ធិសភាពម្នាក់មកពីគណបក្សប្រជាជនកម្ពុជា។ តំបន់ទំនាស់ដីដែលមានទំហំប្រមាណជា ១២.៥០០ អេយ័រ (acres) នោះ គឺជាផ្នែកមួយនៃសម្បទានដីសេដ្ឋកិច្ចនៅឃុំស្រែខ្ទុំ ដែលផ្តល់ដោយរដ្ឋាភិបាលនៅឆ្នាំ២០០៧ ទៅឱ្យក្រុមហ៊ុន រឹទ្ធី គិរីសីមា។ នៅពេលនោះ ក្រុមវាស់វែងដី បានចូលទៅក្នុងតំបន់ ហើយបានចាប់ផ្តើមបែងចែក ភូមិទាំងនោះ សម្រាប់ធ្វើចំការកៅស៊ូតាមសំណើ ហើយមកដល់ឆ្នាំ២០០៩ ក្រុមហ៊ុននេះបានបញ្ជូនរថយន្តឈូសដីដំបូងរបស់ខ្លួនចូលមកក្នុងតំបន់នោះ។ មានអ្នកភូមិខ្លះ បានអះអាងថាពួកគាត់បានទិញដីរបស់ខ្លួនតាំងពីយូរមកហើយ ល្មមអាចឱ្យពួកគាត់មានកម្មសិទ្ធិលើដីនោះតាមច្បាប់ភូមិបាលឆ្នាំ២០០១ ព្រមទាំងបានអះអាងថា ពួកគេមានឯកសារដែលបញ្ជាក់ភ័ស្តុតាងអំពីការទាមទាររបស់ពួកគាត់ ប៉ុន្តែអាជ្ញាធរដែនដី បានបដិសេធមិនផ្តល់កម្មសិទ្ធិឱ្យពួកគាត់ឡើយ។ ទាំងរដ្ឋាភិបាល ទាំងតុលាការ ពុំបានផ្តល់ទីកន្លែងឱ្យពួកគាត់អាចធ្វើការតវ៉ាចំពោះសេចក្តីសម្រេចរបស់អាជ្ញាធរដែនដី ឬយ៉ាងហោចណាស់ ធ្វើការទាមទាររបស់ពួកគាត់ឡើយ។ មកដល់ដំណាច់ឆ្នាំនេះ រដ្ឋាភិបាលពុំបានផ្តល់សំណងជាទម្រង់អ្វីមួយដល់អ្នកភូមិឡើយ ប៉ុន្តែ អាជ្ញាធរដែនដីបានបង្កើតគណៈកម្មាធិការមួយ ដើម្បីជួយដោះស្រាយបញ្ហានេះ។

នៅថ្ងៃទី០៩ ខែមិថុនា មានការប៉ះទង្គិចមួយរវាងនគរបាល និងអ្នកភូមិ នៅខេត្តកំពង់ស្ពឺ នាំឱ្យមានរបួសទាំងសងខាង។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយបានរាយការណ៍ថា អ្នកភូមិចំនួន ៩០០នាក់ បានបិទផ្លូវលេខ៥១ ដើម្បីប្រឆាំងនឹងការអនុវត្តដីការបង្គាប់របស់តុលាការ ឱ្យដេញពួកគាត់ចេញពីដីដែលមានទំនាស់ ហើយបានវាយប្រហារលើនគរបាលនឹងដុំថ្ម កាំបិត ខ្វែវ និងដំបង។ នគរបាលបានបាញ់ទៅលើបាតុករ ប៉ុន្តែ បានគេចខ្លួនទៅវិញក្រោយពីខកខានមិនបានអនុវត្តដីការបង្គាប់របស់តុលាការនោះ។

**ផ្នែកទី២៖ ការគោរពសេរីភាពពលរដ្ឋស៊ីវិលរួមមាន៖**

## ក. សេរីភាពបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន

## ស្ថានភាពសេរីភាពបញ្ចេញមតិ និងសារព័ត៌មាន

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងអំពីសេរីភាពបញ្ចេញមតិ និងសារព័ត៌មាន ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង សិទ្ធិទាំងនេះមិនត្រូវបានគោរពឱ្យជាប់លាប់ឡើយ។

ច្បាប់ស្តីពីសារព័ត៌មានឆ្នាំ១៩៩៥ ហាមប្រាមចំពោះការត្រួតពិនិត្យការបោះពុម្ពផ្សាយជាមុន ឬការដាក់ពន្ធនាគារចំពោះការបញ្ចេញមតិ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលបានប្រើប្រាស់ក្រមព្រហ្មទណ្ឌដើម្បីផ្តន្ទាទោសប្រជាពលរដ្ឋពីបទបរិហារកេរ្តិ៍ ការផ្សព្វផ្សាយព័ត៌មានមិនពិត និងការញុះញង់។ ក្រមព្រហ្មទណ្ឌ ពុំមានចែងអំពីការដាក់ពន្ធនាគារចំពោះបទបរិហារកេរ្តិ៍នោះទេ ប៉ុន្តែ មានចែងអំពីបទញុះញង់ ឬការផ្សព្វផ្សាយព័ត៌មានមិនពិត ដែលជាប់ទោសដាក់ពន្ធនាគាររហូតដល់ទៅ ៣ឆ្នាំ។ ចៅក្រមក៏អាចបញ្ជាឱ្យមានការផាកពិន័យផងដែរ ដែលអាចនាំទៅការដាក់ពន្ធនាគារ ប្រសិនបើមិនបានបង់។

<u>សេរីភាពបញ្ចេញមតិ៖</u> រដ្ឋធម្មនុញ្ញកំណត់ថា ការបញ្ចេញមតិដោយសេរី មិនត្រូវប៉ះពាល់ដល់សន្តិសុខសាធារណៈឡើយ។ រដ្ឋធម្មនុញ្ញក៏ប្រកាសផងដែរថា ព្រះមហាក្សត្រ "មិនអាចរំលោភបំពានបាន" ឡើយ ចំណែកឯសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃមួយដែលអនុលោមតាមច្បាប់បរិហារកេរ្តិ៍ បញ្ជាក់អំពីការកំណត់ទាំងនេះ ហើយបានហាមឃាត់អ្នកបោះពុម្ពផ្សាយ និងនិពន្ធនាយកមិនឱ្យផ្សព្វផ្សាយរឿងមិនពិត ដែលប្រមាថ ឬបរិហារកេរ្តិ៍អ្នកដឹកនាំ និងស្ថាប័នរដ្ឋាភិបាលដែរ។

នៅថ្ងៃទី២៥ ខែមករា តុលាការខេត្តកំពង់ឆ្នាំង បានកាត់ទោសលោក សម ចាន់គា ជាបុគ្គលិករបស់អង្គការអាដហុកពីបទបរិហារកេរ្តិ៍ ដោយសារយោបល់ដែលបានធ្វើ ទាក់ទងនឹងទំនាស់ដីជាមួយក្រុមហ៊ុន KCD អន្តរជាតិ។ ក្រុមហ៊ុននេះ បានចោទប្រកាន់ថា លោក សម ចាន់គា បានប្រាប់វិទ្យុអាស៊ីសេរីថា ក្រុមហ៊ុននេះ "កំពុងកាប់ឆ្ការព្រៃ" លើដីមានទំនាស់ដែលក្រុមហ៊ុន KDC បានតវ៉ាថា ខ្លួនគ្រាន់តែ "ធ្វើប្រឡាយ" ជុំវិញតំបន់នោះប៉ុណ្ណោះ។ តុលាការបានបញ្ជាឱ្យលោក សម ចាន់គា បង់ប្រាក់ពិន័យចំនួនមួយលានរៀល (២៤៤ ដុល្លារអាមេរិក) និង ៣លានរៀលបន្ថែមទៀត (៧៣១ដុល្លារអាមេរិក) ទៅឱ្យក្រុមហ៊ុនជាសំណង។ តាម របាយការណ៍ ក្រុមហ៊ុននេះជារបស់លោកស្រី ជា ខេង ជាភរិយារបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

<u>សេរីភាពសារព័ត៌មាន៖</u> គណបក្សនយោបាយធំៗទាំងអស់មានលទ្ធភាពផ្សព្វផ្សាយព័ត៌មាន បោះពុម្ពផ្សាយសមស្រប និងជាទៀងទាត់។ សារព័ត៌មានជាភាសាខ្មែរធំៗ ទាំងអស់ សុទ្ធតែបានទទួលការគាំទ្រផ្នែកថវិកាពីបុគ្គល ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយគណបក្សនយោបាយណាមួយ ហើយមានការជាប់ពាក់ព័ន្ធផ្នែកនយោបាយ។ មានសារព័ត៌មានជាភាសាខ្មែរប្រមាណជា ២០ បានបោះពុម្ពផ្សាយជាទៀងទាត់។ នៅអំឡុងឆ្នាំនេះ មានសារព័ត៌មានគាំទ្រគណបក្សប្រឆាំងចំនួន ៣ ធ្វើការពុម្ពផ្សាយជាទៀងទាត់ ធៀបនឹងឆ្នាំ២០១០ ដែលមានតែមួយគត់។ មានបណ្តាញព័ត៌មានគាំទ្រគណបក្សប្រឆាំងមួយទៀត មាននៅក្នុងវេបសាយត៍ ប៉ុន្តែ បោះពុម្ពផ្សាយសារព័ត៌មានយូរៗម្តង។ ទោះបីជាសារព័ត៌មានធំៗទាំង៥ ដែលមានការផ្សព្វផ្សាយច្រើន ត្រូវចាត់ទុកថា ជាសារព័ត៌មានគាំទ្រគណបក្សប្រជាជនកម្ពុជាក៏ដោយ ក៏សារព័ត៌មានភាគច្រើនបំផុត បានរិះគន់រដ្ឋាភិបាល ជា

ពិសេសទាក់ទងនឹងអំពើពុករលួយ និងលទ្ធកម្មដី។ នាយករដ្ឋមន្ត្រី មេដឹកនាំគណបក្សរាជនិយម និងគណបក្សប្រឆាំង ជាញឹកញាប់ ទទួលការវាយប្រហារ។

រដ្ឋាភិបាល កងកម្លាំងយោធា និងគណបក្សកាន់អំណាច នៅតែបន្តគ្របដណ្តប់លើបណ្តាញផ្សព្វផ្សាយព័ត៌មាន និងមានឥទ្ធិពលលើខ្លឹមសារនៃការផ្សព្វផ្សាយដដែល។ មានស្ថានីយទូរទស្សន៍ក្នុងស្រុកចំនួន១០ និងស្ថានីយវិទ្យុប្រមាណជា៥០។ ស្ថានីយទូរទស្សន៍ និងវិទ្យុ ស្ទើរតែទាំងអស់ ស្ថិតក្រោមការត្រួតត្រា និងឥទ្ធិពលរបស់គណបក្សប្រជាជនកម្ពុជា ទោះបីជាចំនួនតូចមានភាពឯករាជ្យ ឬពាក់ព័ន្ធនឹងគណបក្សដទៃទៀតក៏ដោយ។

<u>ការត្រួតពិនិត្យការបោះពុម្ពផ្សាយ ឬការរឹតត្បិតខ្លឹមសារ៖</u> នៅថ្ងៃទី០៩ ខែសីហា ក្រសួងមហាផ្ទៃ បានផ្អាកសមាគមធាងត្នោត (STT) ដែលជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយនៅក្នុងឆ្នាំ តាមការចោទប្រកាន់ថាបណ្តាលមកពីការងារតស៊ូមតិរបស់អង្គការនេះទាក់ទងនឹងករណីទំនាស់ដីធ្លី ប៉ុន្តែ តាមផ្លូវការ ដោយសារសមាគមធាងត្នោតខកខានមិនបានបំពេញតាមលក្ខខណ្ឌរដ្ឋបាល។ ក្រសួងនេះបានចោទសមាគមធាងត្នោតអំពីការព្យាយាមរារាំងគម្រោងស្ពានផ្លូវដែកដែលទទួលបានមូលនិធិពីធនាគារអភិវឌ្ឍន៍អាស៊ី ដោយលើកទឹកចិត្តឱ្យជនត្រូវផ្លាស់ទីលំនៅដាក់ពាក្យបណ្តឹង។ ក្រសួងមានចេញសេចក្តីថ្លែងការណ៍មួយនៅថ្ងៃទី១៣ ខែសីហា ដែលបានចោទប្រកាន់សមាគមធាងត្នោតពីបទ "ញុះញង់អ្នកភូមិ" ដែលត្រូវបាត់បង់លំនៅឋានដោយសារគម្រោងស្ពានផ្លូវដែកនោះ។

នៅអំឡុងឆ្នាំនេះ ពុំមានរបាយការណ៍ថា អ្នកសារព័ត៌មាន អ្នកបោះពុម្ពផ្សាយ ឬអ្នកចែកចាយសារព័ត៌មាន ទទួលរងការបៀតបៀន ឬការបំភិតបំភ័យទេ ប៉ុន្តែ អ្នករាយការណ៍ និងនិពន្ធនាយក បានសារភាពជា ឯកជនអំពីការត្រួតពិនិត្យបោះពុម្ពផ្សាយដោយខ្លួនមួយចំនួន ដោយសារភ័យខ្លាចការសងសឹកអំពីរដ្ឋាភិបាល។

<u>ច្បាប់បរិហារកេរ្តិ៍/សន្តិសុខជាតិ៖</u> ទាក់ទងនឹងបណ្តឹងបរិហារកេរ្តិ៍ ដែលបានធ្វើឡើងដោយលោករដ្ឋមន្ត្រី ការបរទេស ហោ ណាំហុង ប្រឆាំងនឹងមេដឹកនាំគណបក្សប្រឆាំង សម រង្ស៊ី នៅថ្ងៃទី២៥ ខែមេសា តុលាការ រាជធានីភ្នំពេញ បានកាត់ទោសលោក សម រង្ស៊ី ដោយកំបាំងមុខ ដាក់ពន្ធនាគាររយៈពេល ២ឆ្នាំពីបទញុះញង់ និងការចោទថា លោក សម រង្ស៊ី បានបរិហារកេរ្តិ៍លោករដ្ឋមន្ត្រីក្រសួងការបរទេស។

នៅថ្ងៃទី០២ ខែមិថុនា តុលាការកំពូលបានតម្កល់សាលក្រមបរិហារកេរ្តិ៍របស់សាលាឧទ្ធរណ៍ប្រឆាំងនឹងលោកស្រី មូរ សុខហួ អ្នកតំណាងរាស្ត្រគណបក្សប្រឆាំងចំពោះយោបល់ដែលលោកស្រីបានធ្វើឡើងនៅក្នុងសន្និសីទសារព័ត៌មានមួយ ដែលត្រូវបានចោទប្រកាន់ថា បានបរិហារកេរ្តិ៍ លោកនាយករដ្ឋមន្ត្រី។ តុលាការបានបញ្ជាឱ្យ លោកស្រី មូរ សុខហួ បង់ប្រាក់ពិន័យចំនួន ៨លានរៀល (១.៩៥០ដុល្លារអាមេរិក) ព្រមទាំងសំណងចំពោះលោកនាយករដ្ឋមន្ត្រីចំនួន ៨,៥លានរៀល (២.០៧០ដុល្លារអាមេរិក)។ លោកស្រី មូរ សុខហួ បដិសេធពុំព្រមបង់ឱ្យ។ នៅថ្ងៃទី១៥ ខែកក្កដា តុលាការរាជធានីភ្នំពេញ បានស្នើឱ្យរដ្ឋសភាកាត់ប្រាក់បៀវត្សរ៍លោកស្រី មូរ សុខហួ ក្នុងនាមជាអ្នកតំណាងរាស្ត្រ ដើម្បីទូទាត់សងប្រាក់សំណង ដែលបានជំពាក់លោកនាយករដ្ឋមន្ត្រី រដ្ឋសភាបានអនុម័តសំណើនោះ នៅថ្ងៃទី២៩ ខែកក្កដា រួចចាប់ផ្តើមកាត់ប្រាក់ចំនួន ៤លានរៀល (៩៧៥ដុល្លារអាមេរិក) ក្នុងមួយខែ ពីប្រាក់បៀវត្សរ៍លោកស្រី មូរ សុខហួ។ លោកស្រី មូរ សុខហួ បានស្វែងរកការស្តារអភ័យឯកសិទ្ធិរបស់គាត់ ប៉ុន្តែ ពុំទាន់មានការចាត់វិធានការលើករណីនេះឡើយ។

## សេរីភាពប្រើប្រាស់អ៊ីនធឺណិត

ជាទូទៅ គ្មានការរឹតត្បិតរបស់រដ្ឋាភិបាលលើលទ្ធភាពប្រើប្រាស់អ៊ីនធឺណិតទេ ឬគ្មានរបាយការណ៍គួរឱ្យជឿបានថា រដ្ឋាភិបាលបានត្រួតពិនិត្យអ៊ីមែល ឬបន្ទប់សន្ទនាតាមអ៊ីនធឺណិតឡើយ។

បុគ្គល និងក្រុមនានា អាចចូលរួមក្នុងការបញ្ចេញទស្សនៈតាមរយៈអ៊ីនធឺណិត រួមទាំងតាមរយៈអ៊ីមែលផងដែរ។

ទោះជាយ៉ាងណាក៏ដោយ មានការចោទប្រកាន់គួរឱ្យជឿបានថា តួអង្គរដ្ឋាភិបាលបានដាក់សម្ពាធដោយជោគជ័យលើក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតឱ្យរាំងខ្ទប់លទ្ធភាពប្រើប្រាស់រយៈពេលពីរបីថ្ងៃ នៅខែកុម្ភៈ ចំពោះវែបសាយត៍ដ៏ល្បី (ហៅថា KI-Media) ដែលរិះគន់រដ្ឋាភិបាល។ លទ្ធភាពប្រើប្រាស់នេះ ត្រូវបើកឡើងវិញ យ៉ាងឆាប់រហ័ស ក្រោយពីការទាមទារប្រឆាំងជាសាធារណៈដោយបណ្តាញសារព័ត៌មាន អង្គការមិនមែន រដ្ឋាភិបាល និងមន្ត្រីរដ្ឋាភិបាល ហើយគ្មានឧប្បត្តិហេតុបែបនេះកើតមានឡើងទៀតឡើយនៅអំឡុងឆ្នាំនេះ។

## សេរីភាពសិក្សា និងព្រឹត្តិការណ៍វប្បធម៌

ជាទូទៅ គ្មានការរឹតត្បិតពីសំណាក់រដ្ឋាភិបាលទៅលើសេរីភាពសិក្សា ឬព្រឹត្តិការណ៍វប្បធម៌ឡើយ។ ទោះជាយ៉ាងណាក៏ដោយ អ្នកសិក្សាហាក់ដូចជាមានការប្រយ័ត្នប្រយែង នៅពេលបង្រៀនមុខវិជ្ជាទាក់ទងនឹងនយោបាយ ដោយសារភ័យខ្លាចប៉ះពាល់ដល់អ្នកនយោបាយ។ ជាងនេះទៅទៀត រដ្ឋាភិបាលបានហាមឃាត់ការចាក់ផ្សាយជាសាធារណៈនូវភាពយន្តដ៏ចម្រូងចម្រាស់មួយអំពីការធ្វើឃាតលើលោក ជា វិជ្ជា កាលពីឆ្នាំ ២០០៤ ដែលជាមេដឹកនាំកម្មករ-និយោជិតដ៏លេចធ្លោម្នាក់ (សូមមើលផ្នែក ១.ង)។

## ខ. សេរីភាពប្រមូលផ្តុំដោយសន្តិវិធី និងសេរីភាពសមាគម

## សេរីភាពប្រមូលផ្តុំ

រដ្ឋធម្មនុញ្ញមានចែងអំពីសេរីភាពប្រមូលផ្តុំដោយសន្តិវិធី ប៉ុន្តែ មានពេលខ្លះ រដ្ឋាភិបាលពុំបានគោរពសិទ្ធិនេះទេ នៅក្នុងការអនុវត្តជាក់ស្តែង។

ច្បាប់តម្រូវឱ្យមានការផ្តល់ការអនុញ្ញាតជាមុន មុនពេលដង្ហែរក្បួនតវ៉ា ឬបាតុកម្ម។ មានបទប្បញ្ញត្តិមួយបានតម្រូវឱ្យមានការជូនដំណឹងរយៈពេល ៥ថ្ងៃជាមុនសម្រាប់បាតុកម្មដោយសន្តិវិធីភាគច្រើនបំផុត ចំណែកឯបទប្បញ្ញត្តិមួយទៀត តម្រូវឱ្យមានការជូនដំណឹងរយៈពេល ១២ម៉ោង សម្រាប់ការប្រមូលផ្តុំជាបន្ទាន់នៅក្នុងបរិវេណឯកជន ឬនៅទីតាំងតវ៉ាដោយសន្តិវិធី ដែលបានកំណត់ទុកជាស្រេច នៅតាមខេត្តនីមួយៗ និងមានដាក់កំហិតចំនួនអ្នកចូលរួមប្រមូលផ្តុំចំនួន ២០០នាក់។ តាមច្បាប់ រដ្ឋាភិបាលថ្នាក់ខេត្ត ឬរាជធានី មានអំណាចចេញការអនុញ្ញាតតាមឆន្ទានុសិទ្ធិរបស់ខ្លួន។ នៅក្នុងការអនុវត្តជាក់ស្តែង ជាពិសេស នៅទីក្រុងភ្នំពេញ មន្ត្រីរដ្ឋាភិបាលថ្នាក់ទាបត្រូវគោរពតាមរដ្ឋាភិបាលថ្នាក់ជាតិ ជាអ្នកសម្រេច និងបដិសេធសំណើ លើកលែងតែរដ្ឋាភិបាលថ្នាក់ជាតិបានអនុញ្ញាតច្បាស់លាស់ចំពោះការប្រមូលផ្តុំនោះ។ តាមទម្លាប់ រដ្ឋាភិបាលមិនបានចេញការអនុញ្ញាតឱ្យក្រុមដែលរិះគន់គណបក្សកាន់អំណាចឡើយ ឬប្រទេសដែលរដ្ឋាភិបាលមានទំនាក់ទំនងជាមិត្តជាមួយឡើយ។ អាជ្ញាធរ

បានលើកឡើងពីតម្រូវការរក្សាស្ថិរភាព និងសន្តិសុខសាធារណៈជាហេតុផលចំពោះការបដិសេធមិនចេញការអនុញ្ញាតឱ្យ។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់មិនបានកំណត់អំពីពាក្យ ស្ថិរភាព ឬសន្តិសុខសាធារណៈ ដើម្បីជួយអាជ្ញាធរក្នុងការអនុវត្តច្បាប់ឡើយ។ នគរបាលបានបំបែកក្រុមដោយកម្លាំងដែលបានប្រមូលផ្តុំដោយគ្មានការអនុញ្ញាត ក្នុងករណីខ្លះ បង្កឱ្យមានរបួសស្នាមបន្តិចបន្តួចចំពោះបាតុករមួយចំនួន។

នៅថ្ងៃទី០៩ ខែកញ្ញា អង្គការក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF) ដែលជាអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុកមួយនោះ បានដាក់សំណើជាផ្លូវការទៅសាលារាជធានីភ្នំពេញ ដើម្បីប្រារព្ធទិវាលំនៅឋានពិភពលោក នៅសួនសាធារណៈមួយ។ អង្គការក្រុមការងារពិសេសសិទ្ធិលំនៅឋានមានគម្រោងអញ្ជើញអ្នកចូលរួមប្រមាណជា ៥០០នាក់ មកពីសហគមន៍ផ្សេងៗ ដែលមានភាពស្មុគស្មាញក្នុងទំនាស់ដីធ្លី។ ព្រឹត្តិការណ៍នេះ ត្រៀមនឹងបង្ហាញវាគ្មិនកត្តិយសមួយរូបដើម្បីពិភាក្សាអំពីការប្រែប្រួលអាកាសធាតុ និងបញ្ហាដីធ្លី ហើយមិនពាក់ព័ន្ធដល់ការដង្ហែរក្បួនដ៏ច្រើនតាមដងផ្លូវសាធារណៈឡើយ។ សាលារាជធានី បានបដិសេធមិនផ្តល់ការអនុញ្ញាត ដោយគ្មានការពន្យល់អ្វីឡើយ។

នៅថ្ងៃទី២១ ខែមេសា មានអ្នកតវ៉ាប្រមាណជា ១០០ ទៅ ២០០នាក់ បានប្រមូលផ្តុំគ្នានៅមុខសាលាក្រុងភ្នំពេញ ដើម្បីទាមទារជួបជាមួយលោកអភិបាលក្រុង កែប ជុតិមា និងដើម្បីសម្តែងការកើតទុក្ខមិនសុខចិត្តអំពីសម្បទានដីបឹងកក់។ បាតុកម្មនោះ ក៏បានបែកសាយភាយ ធ្វើឱ្យរាំងស្ទះដល់ការធ្វើចរាចរណ៍នៅលើដងផ្លូវសាធារណៈធំមួយ។ នៅពេលដែលបាតុករ ខកខានមិនបានយកចិត្តទុកដាក់ចំពោះការព្រមានឱ្យបំបែកហ្វូងនោះ នគរបាលបានចល័តចូលមកព័ទ្ធពួកគាត់។ បំពាក់ដោយខែលបង្ក្រាបកុប្បកម្ម និងដំបងឆក់ នគរបាលបានឈរទល់ស្មាគ្នាដើរសំដៅក្នុងគោលបំណងរាំងខ្ទប់បាតុករ និងបញ្ចុះបញ្ចូលពួកគេឱ្យចាកចេញ។ ក្រុមបាតុករបានតបតវិញដោយរុញច្រានមន្ត្រីនគរបាល បន្ទាប់មកឧប្បត្តិហេតុនោះ ក៏បានប្រែក្លាយជាអំពើហិង្សា។

គិតមកត្រឹមខែតុលា អង្គការអាដហុកបានរាយការណ៍អំពីបាតុកម្មចំនួន ៨១ ដែលភាគច្រើនបំផុតទាក់ទងនឹងទំនាស់ដីធ្លី និងវិវាទការងារ។

## សេរីភាពសមាគម

រដ្ឋធម្មនុញ្ញផ្តល់សេរីភាពសមាគម ហើយជាទូទៅ រដ្ឋាភិបាលបានគោរពសិទ្ធិនេះនៅក្នុងការអនុវត្តជាក់ស្តែង ប៉ុន្តែ រដ្ឋាភិបាលមិនបានអនុវត្តប្រការនេះ ទាក់ទងនឹងសិទ្ធិរបស់កម្មករ-និយោជិតទេ។ (សូមមើលផ្នែក ៧.ក)។

នៅខែធ្នូ ឆ្នាំ២០១០ រដ្ឋាភិបាលបានបញ្ចេញសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីឱ្យមានការបញ្ចេញយោបល់ជាសាធារណៈ។ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ បានសម្តែងកង្វល់យ៉ាងខ្លាំងអំពីសំណើច្បាប់នេះ ដែលរួមមានពាក្យពេចន៍ដែលតម្រូវឱ្យមានលក្ខខណ្ឌរាយការណ៍ជាបន្ទុកយ៉ាងធ្ងន់លើអង្គការមិនមែនរដ្ឋាភិបាល រារាំងសមាគមដែលមានសមាជិកតិចជាង ២១នាក់ មិនឱ្យបានទទួលស្ថានភាពស្របច្បាប់ និងដាក់របាំងចំពោះការចុះបញ្ជិការរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស។ រដ្ឋាភិបាលបរទេស បានសម្តែងកង្វល់ថា សំណើច្បាប់នេះ អាចបង្កើនការរឹតត្បិតកាន់តែខ្លាំងរបស់រដ្ឋាភិបាលលើសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលបរទេស។ នៅអំឡុងឆ្នាំនេះ រដ្ឋាភិបាលបានកែសម្រួលសេចក្តីព្រាងច្បាប់នេះជាច្រើនរបៀប រួមមាន ការកំណត់អោយមានសិទ្ធិតវ៉ាអំពីសេចក្តីសម្រេចចិត្តមិនទទួលចុះបញ្ជី និងមិនរាប់

បញ្ចូលអង្គការមិនមែនរដ្ឋាភិបាលតូចៗ (ហៅថា អង្គការតាមសហគមន៍) និង អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមានរយៈពេលខ្លី ចេញពីវិសាលភាពនៃច្បាប់នេះ។ សេចក្តីព្រាងច្បាប់នេះ នៅតែមានបញ្ហាដដែលចំពោះ អង្គការសង្គមស៊ីវិលជាច្រើន។ នៅខែធ្នូ លោកនាយករដ្ឋមន្ត្រី បានប្រកាសថា ការពិគ្រោះយោបល់រវាងរដ្ឋាភិបាល និងសង្គមស៊ីវិល លើសេចក្តីព្រាងច្បាប់នេះនឹងនៅបន្តរហូតដល់មានការ សម្រេចមតិឯកច្ឆន្ទ។ ក្រសួងមហាផ្ទៃកំពុងពិនិត្យមើលកែសម្រួលសេចក្តីព្រាងច្បាប់នេះនៅឡើយ។

**គ. សេរីភាពសាសនា**

សូមមើល *របាយការណ៍ស្តីពីសេរីភាពសាសនាអន្តរជាតិ* នៅគេហទំព័រ www.state.gov/j/drl/irf/rpt.

**ឃ. សេរីភាពក្នុងការដើរហើរ ជនភៀសខ្លួនក្នុងស្រុក ការការពារជនភៀសខ្លួន និងជនគ្មានសញ្ជាតិ**

ច្បាប់ចែងពីសេរីភាពដើរហើរនៅក្នុងប្រទេស ការធ្វើដំណើរទៅបរទេស និរប្រវេសន្ត និងមាតុភូមិនិវត្ត ហើយរដ្ឋាភិបាល ជាទូទៅ បានគោរពសិទ្ធិទាំងនេះនៅក្នុងការអនុវត្តជាក់ស្តែង។ រដ្ឋាភិបាលបានសហការជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) និងអង្គការមនុស្សធម៌ដទៃទៀតក្នុងការផ្តល់ការការពារ និងជំនួយដល់ជនភៀសខ្លួនក្នុងស្រុក ជនភៀសខ្លួន ជនភៀសខ្លួនមាតុភូមិនិវត្ត អ្នកស្វែងសិទ្ធិជ្រកកោន ជនគ្មានសញ្ជាតិ និងជនពាក់ព័ន្ធដទៃទៀត។

<u>ការនិរទេស៖</u> រដ្ឋធម្មនុញ្ញហាមឃាត់ចំពោះការនិរទេសដោយបង្ខំ ចំណែករដ្ឋាភិបាលពុំបានប្រើប្រាស់ការនិរទេសដោយបង្ខំឡើយ។ មេដឹកនាំបក្សប្រឆាំង លោក សម រង្ស៊ី ត្រូវបានដកហូតអភ័យឯកសិទ្ធិជាតំណាងរាស្ត្រនៅចុងឆ្នាំ២០០៩ ហើយបាននឹងកំពុងរស់នៅស្វ័យនិរទេសខ្លួន តាំងពីមុនពេលនោះមកម្ល៉េះ។

**ការការពារជនភៀសខ្លួន**

<u>ការទទួលបានសិទ្ធិជ្រកកោន៖</u> ច្បាប់ប្រទេសកម្ពុជា មានចែងអំពីការផ្តល់សិទ្ធិជ្រកកោន ឬឋានៈជាជនភៀសខ្លួន ហើយរដ្ឋាភិបាល បានបង្កើតប្រព័ន្ធមួយសម្រាប់ផ្តល់ការការពារដល់ជនភៀសខ្លួន។ ប្រព័ន្ធនេះនៅមានលក្ខណៈក្មេងខ្ចីនៅឡើយ ចំណែកឯសមត្ថភាពនៅមានកម្រិត នាំឱ្យមានការយឺតយ៉ាវសម្រាប់អ្នកស្វែងរកសិទ្ធិជ្រកកោន។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន នៅបន្តផ្តល់ការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសដទៃទៀតនៅឡើយ។

**ជនគ្មានសញ្ជាតិ**

ប្រទេសកម្ពុជាមានប្រជាជនរស់នៅដែលគ្មានសញ្ជាតិ ហើយរដ្ឋាភិបាលពុំបានអនុវត្តច្បាប់ ឬគោលនយោបាយឱ្យមានប្រសិទ្ធភាព ដើម្បីផ្តល់ឱកាសដល់អ្នកទាំងនោះ បានទទួលសញ្ជាតិឡើយ។ តាមច្បាប់សញ្ជាតិ សញ្ជាតិអាចទទួលបានពីកំណើត ចេញពីម្តាយ និងឪពុក ដែលមិនមែនជាជនជាតិខ្មែរ ប្រសិនបើអ្នកទាំងពីរបានកើត និងរស់នៅស្របច្បាប់នៅកម្ពុជា ឬប្រសិនឪពុក ឬម្តាយ បានទទួលសញ្ជាតិខ្មែរ។

តាមការសិក្សានៅឆ្នាំ២០០៧ ដែលធ្វើឡើងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន បានវាយតម្លៃថា អាចមានជនគ្មានសញ្ជាតិជាច្រើនពាន់នាក់ បានរស់នៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែការវាយតម្លៃពីការសិក្សានេះ បានមកពីភ័ស្តុតាងខ្លីៗ មានប្រភពមកពីអង្គការមិនមែនរដ្ឋាភិបាល និងតំណាងពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ពុំបានចាត់ទុកតួលេខនេះ ថាមានលក្ខណៈប្រាកដប្រជាឡើយ។ ហេតុផលជារួមសម្រាប់ការគ្មានសញ្ជាតិនេះ គឺបណ្តាលមកពីកង្វះខាតឯកសារត្រឹមត្រូវមកពីប្រទេសដើម។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនបានបញ្ជាក់ថា ប្រជាជនគ្មានសញ្ជាតិនៅក្នុងប្រទេស រួមមានភាគច្រើនបំផុត គឺជនជាតិវៀតណាម។ យោងតាមអង្គការមិនមែនរដ្ឋាភិបាលមួយ បុគ្គលដែលគ្មានភ័ស្តុតាងបញ្ជាក់អំពីសញ្ជាតិ ជារឿយៗ គ្មានលទ្ធភាពទទួលបានការងារផ្លូវការ ការអប់រំ ការចុះបញ្ជីអាពាហ៍ពិពាហ៍ សេវាតុលាការ និងកម្មសិទ្ធិដីធ្លីឡើយ។

## ផ្នែកទី៣៖ ការគោរពសិទ្ធិនយោបាយ៖ សិទ្ធិពលរដ្ឋក្នុងការផ្លាស់ប្តូររដ្ឋាភិបាលរបស់ខ្លួន

រដ្ឋធម្មនុញ្ញផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋដើម្បីផ្លាស់ប្តូររដ្ឋាភិបាលរបស់ខ្លួនដោយសន្តិវិធី ហើយជាទូទៅ ប្រជាពលរដ្ឋបានប្រើប្រាស់សិទ្ធិនេះក្នុងការអនុវត្តជាក់ស្តែង តាមរយៈការបោះឆ្នោតជាទៀងទាត់ ផ្អែកតាមគោលការណ៍បោះឆ្នោតជាសកល។

### ការបោះឆ្នោត និងការចូលរួមក្នុងឆាកនយោបាយ

<u>ការបោះឆ្នោតក្នុងពេលថ្មីៗនេះ៖</u> ការបោះឆ្នោតជាតិថ្មីៗបំផុត ដែលបានធ្វើឡើងនៅឆ្នាំ២០០៨ សម្រាប់រដ្ឋសភាជារួម មានលក្ខណៈសន្តិវិធី ដោយមានដំណើរការដែលជាទូទៅ ត្រូវចាត់ទុកថា មានភាពល្អប្រសើរជាងការបោះឆ្នោតកន្លងទៅ។ ប៉ុន្តែ អ្នកអង្កេតការណ៍ជាច្រើន បានធ្វើការកត់សម្គាល់ថា ការបោះឆ្នោតនោះ មិនទាន់ស្របតាមស្តង់ដារអន្តរជាតិទាំងស្រុងនៅឡើយទេ។ ទោះបីជានៅតែមានភាពមិនប្រក្រតីមួយចំនួននៅថ្ងៃបោះឆ្នោតក៏ដោយ ក៏ចំនួននៃភាពមិនក្រក្រតីបានថយចុះ ហើយហាក់ដូចជាមិនប៉ះពាល់ដល់លទ្ធផល ឬឆន្ទៈរបស់អ្នកបោះឆ្នោតឡើយ។

គណបក្សនយោបាយអាចចុះឈ្មោះ ចំណែកឯបុគ្គលមានសេរីភាពប្រកាសបេក្ខភាពរបស់ខ្លួន ដោយគ្មានការរឹតត្បិតអ្វីឡើយ។

<u>គណបក្សនយោបាយ៖</u> អង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយមួយចំនួន បានចោទប្រកាន់ថាសមាជិកនៅក្នុងគណបក្សប្រជាជនកម្ពុជាដ៏មានឥទ្ធិពលបានផ្តល់ផលប្រយោជន៍ដូចជា អំណោយ លទ្ធភាពប្រើប្រាស់ជំនួយសង្គ្រោះបន្ទាន់របស់រដ្ឋាភិបាល និងសម្បទានដីសេដ្ឋកិច្ចជាដើម។ គ្មានរបាយការណ៍អំពីសមាជិកគណបក្សប្រឆាំងដែលបានទទួលសម្បទានដីសេដ្ឋកិច្ចស្រដៀងគ្នានេះទេ។

<u>ការចូលរួមរបស់ស្ត្រី និងជនជាតិភាគតិច៖</u> វប្បធម៌ប្រពៃណី បានកម្រិតតួនាទីរបស់ស្ត្រីក្នុងរដ្ឋាភិបាល ទោះជាយ៉ាងណាក៏ដោយ ស្ត្រីបានចូលរួមក្នុងការបោះឆ្នោតប្រយោលនៅខែឧសភា ឆ្នាំ២០០៩ ដើម្បីជ្រើសរើស

ក្រុមប្រឹក្សាខេត្ត និងស្រុក។ ស្ត្រីទទួលបានអាសនៈ ២៦ ក្នុងចំណោមអាសនៈទាំង ១២៣ នៅក្នុងរដ្ឋសភា និងស្ត្រីទទួលបានអាសនៈ ៩ ក្នុងចំណោមអាសនៈទាំង ៦១ នៅក្នុងព្រឹទ្ធសភា។ មានឧបនាយករដ្ឋមន្ត្រីមួយរូបជាស្ត្រី និងរដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ និងមន្ត្រីគណៈកម្មការជាតិរៀបចំការបោះឆ្នោត ជាស្ត្រីចំនួន ៦២រូប។ ស្ត្រីក៏មានបម្រើការជាទីប្រឹក្សា និងមានចៅក្រម និងព្រះរាជអាជ្ញាជាស្ត្រីចំនួន ៥១នាក់នៅក្នុងតុលាការរាជធានី និងខេត្ត សាលាឧទ្ធរណ៍ និងតុលាការកំពូលផងដែរ។ ទោះបីជាគ្មានអភិបាលខេត្តជាស្ត្រីក៏ដោយ រដ្ឋាភិបាលបានតែងតាំងស្ត្រីជាអភិបាលរង នៅគ្រប់ខេត្តទាំង២៣ និងរាជធានីភ្នំពេញ (មានអភិបាលរងខេត្តមួយចំនួននៅក្នុងខេត្តនីមួយៗ)។ គណៈកម្មការជាតិរៀបចំការបោះឆ្នោត បានរាយការណ៍ថា ស្ត្រីបានកាន់កាប់អាសនៈក្រុមប្រឹក្សាឃុំសង្កាត់ចំនួន ១៥ភាគរយ និង អាសនៈក្រុមប្រឹក្សាស្រុក និងខេត្តចំនួន ១៣ភាគរយ។

មានសមាជិកជាជនជាតិដើមភាគតិចចំនួន ៥នាក់ ដែលក្នុងនោះរួមមានសមាជិកជនជាតិចាម ៤នាក់ និងទំពួនមួយនាក់នៅក្នុងរដ្ឋសភា។ ចំណែកនៅក្នុងព្រឹទ្ធសភា ក៏មានសមាជិកជនជាតិដើមភាគតិចបីរូបដែរ។ យ៉ាងហោចណាស់ មានមន្ត្រីជាន់ខ្ពស់ ៨រូប នៅក្នុងជួររដ្ឋាភិបាល មកពីក្រុមជនជាតិដើមភាគតិច។

## ផ្នែកទី៤៖ អំពើពុករលួយផ្លូវការ និងតម្លាភាពរបស់រដ្ឋាភិបាល

ច្បាប់មានចែងអំពីទោសព្រហ្មទណ្ឌចំពោះអំពើពុករលួយផ្លូវការ ប៉ុន្តែ រដ្ឋាភិបាលមិនបានអនុវត្តច្បាប់នេះប្រកបដោយប្រសិទ្ធភាពទេ ចំណែកឯមន្ត្រី ជាញឹកញាប់ បានចូលរួមក្នុងអំពើពុករលួយ ដោយគ្មានទោសពៃរ៍។

ក្រមព្រហ្មទណ្ឌមានកំណត់និយមន័យអំពីអំពើពុករលួយផ្សេងៗ និងមានចែងអំពីទណ្ឌកម្មដែលត្រូវអនុវត្តចំពោះអំពើពុករលួយទាំងនោះ។ ច្បាប់ប្រឆាំងអំពើពុករលួយ ចែងជាមូលដ្ឋានច្បាប់សម្រាប់ឱ្យក្រុមប្រឹក្សាប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយ (ACU) ទទួល និងស៊ើបអង្កេតបណ្តឹងអំពីអំពើពុករលួយ។ មន្ត្រីសាធារណៈត្រូវជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ។

អំពើពុករលួយត្រូវបានចាត់ទុកថា មានលក្ខណៈរីករាលដាលនៅគ្រប់ផ្នែកនៃសង្គមរួមទាំងនៅក្នុងអង្គនីតិប្រតិបត្តិ អង្គនីតិបញ្ញត្តិ និងតុលាការរបស់រដ្ឋាភិបាល។ មានរបាយការណ៍ថា នគរបាល ព្រះរាជអាជ្ញា ចៅក្រមស៊ើបអង្កេត និងប្រធានអង្គជំនុំជម្រះ បានទទួលសំណូកពីម្ចាស់អាជីវកម្មខុសច្បាប់។ បទពិសោធន៍របស់សាធារណជនជាមួយនឹងអំពើពុករលួយដែលបានរាយការណ៍ឱ្យដឹងមានលក្ខណៈរីករាលដាល ដោយបញ្ជាក់ថាមានអំពើពុករលួយជាច្រើនស្ថិតនៅក្នុងភាពលាក់កំបាំង។ ការទទួលបានប្រាក់បៀវត្សរ៍ស្តួចស្តើងគឺជាកត្តាដែលបានរួមចំណែកដល់ "អំពើពុករលួយដើម្បីរស់" ក្នុងចំណោមមន្ត្រីរាជការថ្នាក់ទាប ចំណែកឯវប្បធម៌គ្មានទោសពៃរ៍បានផ្តល់លទ្ធភាពឱ្យអំពើពុករលួយរីកសាយភាយក្នុងចំណោមមន្ត្រីជាន់ខ្ពស់ផងដែរ។

នៅថ្ងៃទី១២ ខែមករា ឧត្តមសេនីយ៍ឯក ម៉ុក តារា ជាមន្ត្រីជាន់ខ្ពស់ប្រឆាំងគ្រឿងញៀនរបស់ប្រទេសកម្ពុជា ត្រូវបានចាប់ខ្លួន និងដាក់ឃុំរង់ចាំការជំនុំជម្រះក្តី ចំពោះបទល្មើសទាក់ទងនឹងអំពើពុករលួយ និងគ្រឿងញៀន។ គិតមកត្រឹមខែធ្នូ ការជំនុំជម្រះក្តីរបស់លោក នៅរង់ចាំនៅឡើយនៅតុលាការខេត្តបន្ទាយមានជ័យ ហើយលោកអាចប្រឈមមុខនឹងការជាប់ទោសអស់មួយជីវិត ប្រសិនបើត្រូវកាត់ទោសនោះ។

នៅថ្ងៃទី១២ ខែឧសភា អតីតព្រះរាជអាជ្ញាតុលាការខេត្តពោធិ៍សាត់ លោក តុប ច័ន្ទសេរីវុធ ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល ១៩ឆ្នាំ ក្រោយពីបានរកឃើញថា មានទោសទាក់ទងនឹងអំពើពុករលួយ ករណីគំរាមកំហែង និងការដាក់ពន្ធនាគារក្លែងក្លាយ។ សាលក្រមចេញដោយតុលាការខេត្តពោធិ៍សាត់នេះ គឺជាសេចក្តីសម្រេចថ្នាក់ខ្ពស់ជាលើកដំបូងឱ្យចាប់ខ្លួនពីសំណាក់អង្គភាពប្រឆាំងអំពើពុករលួយដែលទើបតែបង្កើតឡើងថ្មីៗនេះ។ ជនខាងលើនេះត្រូវបានចាប់ខ្លួន នៅខែវិច្ឆិកា ឆ្នាំ២០១០ រយៈពេល ៩ខែ ក្រោយពីច្បាប់ប្រឆាំងអំពើពុករលួយ ត្រូវបានអនុម័ត។

ច្បាប់ស្តីពីប័ណ្ណសារជាតិ អនុញ្ញាតឱ្យលទ្ធភាពទទួលបានគ្មានដែនកំណត់នូវឯកសារព័ត៌មាននៅក្នុងប័ណ្ណសារសាធារណៈ។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់នេះ ផ្តល់លទ្ធភាពទទួលបានឯកសាររដ្ឋាភិបាលមិន ជាក់លាក់ដទៃទៀត ដែលមានអាយុកាលលើសពី ២០ឆ្នាំប៉ុណ្ណោះ ចំណែកឯកសារប៉ះពាល់ដល់សន្តិសុខជាតិ និងឯកសារអភិរក្សជីវិត អាចចេញផ្សាយលុះត្រាតែមានអាយុកាលលើសពី ៥០ឆ្នាំ និង ១២០ឆ្នាំ តាមលំដាប់គ្នានៃឯកសារដែលបានរៀបរាប់។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានរាយការណ៍ថា ក្នុងការអនុវត្តជាក់ស្តែង ពួកគេមានការលំបាកក្នុងការទទួលព័ត៌មាន ជាញឹកញាប់ រដ្ឋាភិបាលមិនឆ្លើយតប ឬមិនអាចឆ្លើយតបចំពោះការស្នើព័ត៌មានបានទេ។

## ផ្នែកទី៥៖ អាកប្បកិរិយារបស់រដ្ឋាភិបាលទាក់ទងនឹងការស៊ើបអង្កេតជាអន្តរជាតិ និងរបស់អង្គការមិនមែនរដ្ឋាភិបាលអំពីការចោទប្រកាន់ការរំលោភសិទ្ធិមនុស្ស

មានអង្គការសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិមួយចំនួន ដែលជាទូទៅ បានធ្វើប្រតិបត្តិការដោយគ្មានការរឹតត្បិតពីសំណាក់រដ្ឋាភិបាល បានធ្វើការស៊ើបអង្កេត និងបោះពុម្ពផ្សាយរបកគំហើញរបស់ខ្លួនអំពីករណីសិទ្ធិមនុស្ស។ ជារឿយៗ មន្ត្រីរដ្ឋាភិបាល បានសហការជាមួយបុគ្គលិកសិទ្ធិមនុស្សក្នុងការស៊ើបអង្កេតរបស់ខ្លួន ទោះជាយ៉ាងណាក៏ដោយ ក៏មានរបាយការណ៍ជាច្រើននិយាយអំពីការខ្វះកិច្ចសហការ ហើយក្នុងករណីមួយចំនួន មានការគំរាមកំហែងពីសំណាក់មន្ត្រីរដ្ឋាភិបាលទៀតផង។

មានអង្គការសិទ្ធិមនុស្សប្រមាណជា ៥០ អង្គការដែលប្រតិបត្តិនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែ មានតែមួយចំនួនតូចប៉ុណ្ណោះ ដែលចូលរួមយ៉ាងសកម្មក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាល ឬស៊ើបអង្កេតករណីរំលោភបំពាន។

អង្គការសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិ បានប្រឈមមុខនឹងការគំរាមកំហែង និងការធ្វើទុក្ខបុកម្នេញពីសំណាក់មន្ត្រីមូលដ្ឋាន។ ការគំរាមកំហែង និងការធ្វើទុក្ខបុកម្នេញទាំងនេះ មានទម្រង់ជាការរឹតត្បិត និងការរំខានដល់ ការប្រមូលផ្តុំគ្នាដែលឧបត្ថម្ភដោយអង្គការមិនមែនរដ្ឋាភិបាល ការបំភិតបំភ័យដោយពាក្យសម្តី ការគំរាមចាត់វិធានការតាមផ្លូវច្បាប់ និងការរារាំងដោយការិយាធិបតេយ្យជាដើម។ ខុសពីឆ្នាំមុនៗ គ្មានរបាយការណ៍អំពីមេធាវីដែលបម្រើផលប្រយោជន៍សាធារណៈ ត្រូវបានបដិសេធឱ្យចូលជួបកូនក្តីរបស់ខ្លួន ក្នុងករណីរំលោភសិទ្ធិមនុស្សមួយចំនួនទេ ហើយក៏គ្មានរបាយការណ៍អំពីការប៉ុនប៉ងបំភិតបំភ័យតំណាងអង្គការមិនមែនរដ្ឋាភិបាល មិនឱ្យនិយាយជាមួយបណ្តាញប្រព័ន្ធផ្សព្វផ្សាយអំពីករណីដូចពោលនេះដែរ។

<u>ស្ថាប័នអង្គការសហប្រជាជាតិ និងស្ថាប័នអន្តរជាតិដទៃទៀត៖</u> ជាទូទៅ រដ្ឋាភិបាលបានសហការជាមួយស្ថាប័នរដ្ឋាភិបាលអន្តរជាតិ និងបានអនុញ្ញាតចំពោះទស្សនកិច្ចរបស់តំណាងអង្គការសហប្រជាជាតិ។ លោក Surya

Subedi អ្នករាយការណ៍ពិសេសអំពីសិទ្ធិមនុស្សនៅកម្ពុជារបស់អង្គការសហប្រជាជាតិ បានធ្វើទស្សនកិច្ច នៅខែមករា ខែមិថុនា និងខែធ្នូ ដែលនៅអំឡុងពេលនោះ លោក Subedi បានជួបជាមួយលោកនាយករដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់ដទៃទៀតរបស់រដ្ឋាភិបាល។

<u>ស្ថាប័នសិទ្ធិមនុស្សរបស់រដ្ឋាភិបាល៖</u> រដ្ឋាភិបាលមានស្ថាប័នសិទ្ធិមនុស្សចំនួន ៣ រួមមាន៖ គណៈកម្មាធិការដាច់ដោយឡែកចំនួន ២ ទទួលបន្ទុកការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹង ស្ថាប័នមួយទៀតស្ថិតក្រោមព្រឹទ្ធសភា និងមួយទៀត ស្ថិតក្រោមរដ្ឋសភា ព្រមទាំងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដែលរាយការណ៍ទៅកាន់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី។ គណៈកម្មាធិការទាំងនេះ ពុំមានការប្រជុំជាទៀងទាត់ ឬដំណើរការប្រកបដោយតម្លាភាពឡើយ។ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ប្រគល់របាយការណ៍របស់រដ្ឋាភិបាល ដើម្បីចូលរួមក្នុងដំណើរការពិនិត្យសិទ្ធិមនុស្សជាអន្តរជាតិដូចជា ការពិនិត្យជាទៀងទាត់ជាសកល និងបានចេញការឆ្លើយតបចំពោះរបាយការណ៍ធ្វើឡើងដោយស្ថាប័នរដ្ឋាភិបាលអន្តរជាតិ ប៉ុន្តែ មិនបានធ្វើការស៊ើបអង្កេតអំពីស្ថានភាពសិទ្ធិមនុស្សដោយឯករាជ្យឡើយ។ អង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សដែលគួរឱ្យទុកចិត្តបានចាត់ទុកសមត្ថភាពរបស់គណៈកម្មាធិការរបស់រដ្ឋាភិបាលថា មានកម្រិត។

រដ្ឋាភិបាលបានធ្វើជាម្ចាស់ផ្ទះសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (ECCC) ដែលដំណើរការរួមគ្នាជាមួយអង្គការសហប្រជាជាតិ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពាននៅសម័យខ្មែរក្រហម។ អ្នកសង្កេតការណ៍ខ្លះមានជំនឿថា សេចក្តីអត្ថាធិប្បាយជាសាធារណៈដោយអ្នកដឹកនាំរដ្ឋាភិបាលអំពីបញ្ហាទាក់ទងនឹងអាណត្តិយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា បង្កើតបានជាទម្រង់មួយនៃការជ្រៀតជ្រែកផ្នែកនយោបាយ ទោះជាយ៉ាងណាក៏ដោយ គ្មានភ័ស្តុតាងដែលសេចក្តីអត្ថាធិប្បាយទាំងនោះ បានជ្រៀតជ្រែកចូលទៅក្នុងការងាររបស់តុលាការតាមរបៀបណាមួយនោះទេ។ នៅថ្ងៃទី១០ ខែតុលា ចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា បានលាលែងពីមុខតំណែង។ ទោះបីគាត់បានលើកឡើងថា ហេតុផលសម្រាប់ការលាលែងរបស់គាត់ទាក់ទងនឹងសេចក្តីអត្ថាធិប្បាយជាសាធារណៈដោយថ្នាក់ដឹកនាំរដ្ឋាភិបាលដែលអាចនាំឱ្យមានសំណួរអំពីសមត្ថភាពរបស់គាត់ក្នុងការទប់ទល់ជាមួយនឹងការជ្រៀតជ្រែកផ្នែកនយោបាយក៏ដោយ គាត់ពុំបានចោទប្រកាន់អំពីជ្រៀតជ្រែកជាក់ស្តែងណាមួយឡើយ ហើយនៅពេលដែលគាត់លាលែង គាត់បានប្រឈមមុខនឹងការរិះគន់យ៉ាងខ្លាំងពីសំណាក់ចៅក្រមអន្តរជាតិដទៃទៀតនៅ អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាលចំពោះការប្រព្រឹត្តរបស់គាត់ នៅពេលបំពេញការងារ។

នៅថ្ងៃទី២៧ ខែមិថុនា អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា បានបើកសវនាការករណី០០២ លើអតីត "បងធំទី២" នៃរបបខ្មែរក្រហមលោក នួន ជា និងអតីតរដ្ឋមន្ត្រីក្រសួងការបរទេសលោក អៀង សារី និងអតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចលោកស្រី អៀង ធារីទ្ធ និងអតីតប្រមុខរដ្ឋលោក ខៀវ សំផន ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ។ តុលាការនេះ នៅបន្តពិចារណាការចោទប្រកាន់អតីតមន្ត្រីខ្មែរក្រហម ៥នាក់ផ្សេងទៀត ប៉ុន្តែ ការសម្រេចអំពីការចោទប្រកាន់នេះមិនទាន់បានធ្វើនៅឡើយ។ តុលាការក៏នៅបន្តពិចារណាអំពីបណ្តឹងឧទ្ធរណ៍របស់លោក កាំង ហ្គេចអ៊ាវ (ហៅ ឌុច) ដែលត្រូវកាត់ទោសក្នុងករណី០០១ នៅឆ្នាំ២០១០ ផងដែរ។

## ផ្នែកទី៦៖ ការរើសអើង ការរំលោភបំពានក្នុងសង្គម និងការជួញដូរមនុស្ស

រដ្ឋធម្មនុញ្ញហាមប្រាមចំពោះការរើសអើងទាក់ទងនឹងពូជសាសន៍ យេនឌ័រ ពិការភាព ភាសា ឬឋានៈសង្គម ប៉ុន្តែជាទូទៅ រដ្ឋាភិបាលមិនបានការពារសិទ្ធិទាំងនេះឡើយ។

## ស្ត្រី

<u>អំពើរំលោភសេពសន្ថវៈ និងអំពើហិង្សា៖</u> ច្បាប់ដាក់ទោសព្រហ្មទណ្ឌចំពោះអំពើរំលោភសេពសន្ថវៈ និងការបំពារបំពាន។ ទោះជាយ៉ាងនេះក្តី អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិបាន បានរាយការណ៍ថា អំពើហិង្សាប្រឆាំងស្ត្រី មានដូចជាអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈកើតមានជាទូទៅផងដែរ។ អំពើរំលោភសេពសន្ថវៈត្រូវកាត់ទោសឱ្យជាប់ពន្ធនាគារពី ៥ឆ្នាំ ទៅ ៣០ឆ្នាំ។ អំពើរំលោភសេពសន្ថវៈ ប្តី/ប្រពន្ធមិនត្រូវបានចែងជាក់លាក់នៅក្នុងក្រមព្រហ្មទណ្ឌឡើយ ប៉ុន្តែ អាចធ្វើការចោទប្រកាន់ថាជា "អំពើ រំលោភសេពសន្ថវៈ" "ការបង្ករបួសស្នាម" ឬ "ការបំពារបំពានមិនសមរម្យ"។ យោងតាមច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈប្តី/ប្រពន្ធអាចស្ថិតនៅក្នុងនិយមន័យនៃអំពើហិង្សាក្នុងគ្រួសារដែលរួមបញ្ចូល "ការបំពានផ្លូវភេទ" ផងដែរ។ កម្រមានការចោទប្រកាន់ពីបទរំលោភសេពសន្ថវៈប្តី/ប្រពន្ធតាមក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារណាស់។ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារកំណត់ដាក់ទោសព្រហ្មទណ្ឌចំពោះ អំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែ មិនមានចែងជាក់លាក់អំពីការដាក់ទោសឡើយ។ ប៉ុន្តែ អាចប្រើក្រមព្រហ្មទណ្ឌ ដើម្បីដាក់ទោសចំពោះបទល្មើសអំពើហិង្សាក្នុងគ្រួសារ ដោយដាក់ទោសពន្ធនាគារចាប់ពី ១ឆ្នាំរហូតដល់ ១៥ឆ្នាំ។

ចាប់ពីខែតុលា មក អង្គការមិនមែនរដ្ឋាភិបាលមួយបានទទួលរបាយការណ៍អំពីករណីរំលោភសេពសន្ថវៈចំនួន ៥២១ករណី ។ នៅក្នុងចំណោមករណីទាំងនេះ មាន ៧២ករណី ដោះស្រាយដោយតុលាការ ៣៩ករណី សម្របសម្រួលដោយតុលាការ ឬនគរបាល ហើយករណីដែលនៅសល់នៅរង់ចាំការដោះស្រាយពីតុលាការ។ ចំពោះអំពើហិង្សាក្នុងគ្រួសារ មានរបាយការណ៍ចំនួន ៥៦១ករណី ចាប់ពីខែតុលា មក។ តុលាការដោះស្រាយបានតែ ១២ករណីតែប៉ុណ្ណោះ។ អង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀតបានចងក្រងអំពើហិង្សា ក្នុងគ្រួសារចំនួន ១៦១ករណីដែលប៉ះពាល់ដល់ជនរងគ្រោះចំនួន ១៦១នាក់ ហើយអំពើរំលោភសេពសន្ថវៈចំនួន ៧៨ ករណី ប៉ះពាល់ដល់ជនរងគ្រោះចំនួន ៧៩នាក់នៅក្នុងខេត្តចំនួន ១៣ និងរាជធានីភ្នំពេញនៅត្រឹម ដំណាច់ខែតុលា។ អំពើហិង្សាក្នុងគ្រួសារចំនួន ៦ករណី និងករណីរំលោភសេពសន្ថវៈចំនួន ២ករណីបានបណ្តាលឱ្យជនរងគ្រោះចំនួន ៨នាក់ស្លាប់។ ចាប់ពីខែមិថុនា នាយកដ្ឋានប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៃក្រសួងមហាផ្ទៃបានស្រាវជ្រាវរកឃើញអំពើហិង្សាប្រឆាំងនឹងស្ត្រី និងកុមារចំនួន ២៣៨ករណី ដែលឈានដល់ការចាប់ខ្លួនជនល្មើសចំនួន ២៣៩នាក់ និងបានជួយសង្គ្រោះជនរងគ្រោះចំនួន ២៤៩នាក់។ នៅក្នុងចំណោម ២៣៨ករណី មាន ១៤០ករណីជាករណីរំលោភសេពសន្ថវៈ និងប៉ុនប៉ងរំលោភសេពសន្ថវៈ។ ក្រសួងបានរាយការណ៍ថា ករណីរំលោភសេពសន្ថវៈមួយបានបណ្តាលឱ្យស្លាប់ជនរងគ្រោះ។ ករណីមួយចំនួនទំនងជាបានរាយការណ៍មិនគ្រប់គ្រាន់អំពីវិសាលភាពនៃបញ្ហា ដោយសារការអនុវត្តច្បាប់គ្មានប្រសិទ្ធភាព ការរាយការណ៍អំពីស្ថិតិបទព្រហ្មទណ្ឌមិនគ្រប់គ្រាន់ និងដោយសារស្ត្រីភ័យខ្លាចមិនហ៊ានប្តឹងជនល្មើស។ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា ការអនុវត្តច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារមានភាពទន់ខ្សោយ អាជ្ញាធរបន្តបញ្ច្រៀសការជាប់ពាក់ព័ន្ធនៅក្នុងជម្លោះក្នុងគ្រួសារ ហើយជាញឹកញាប់ ជនរងគ្រោះស្ទាក់ស្ទើរក្នុងការដាក់ពាក្យបណ្តឹងជាផ្លូវការ។

នៅថ្ងៃទី០៦ ខែមេសា តុលាការក្រុងភ្នំពេញបានចោទប្រកាន់ និងកាត់ទោសកំបាំងមុខលោក អួន ដារ៉ា និងលោក ចាន់ ណារិទ្ធិ ដែលជាមន្ត្រីនគរបាលខណ្ឌមានជ័យ ក្រុងភ្នំពេញ ឱ្យជាប់ពន្ធនាគារ ៧ឆ្នាំពីបទ រំលោភសេពសន្ថវៈលើស្ត្រីអាយុ ១៩ឆ្នាំនៅខែវិច្ឆិកា ឆ្នាំ២០០៩។

រដ្ឋាភិបាលបានគាំទ្រអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់ការបណ្តុះបណ្តាលដល់ស្ត្រីក្រីក្រងាយរងគ្រោះពី ការរំលោភប្តី/ប្រពន្ធ ពេស្យាចារ្យ និងការជួញដូរ។ ក្រសួងកិច្ចការនារីបានសម្របសម្រួលជាមួយអង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកដើម្បីបង្កើតកម្មវិធីចាក់ផ្សាយតាមវិទ្យុ និងទូរទស្សន៍អំពីបញ្ហាស្ត្រី។

<u>ការបៀតបៀនផ្លូវភេទ៖</u> ក្រមព្រហ្មទណ្ឌដាក់ទោសព្រហ្មទណ្ឌចំពោះការបៀតបៀនផ្លូវភេទ ដោយដាក់ពន្ធនាគារពី ៦ថ្ងៃទៅ ៣ខែ និងពិន័យជាទឹកប្រាក់ចំនួនពី ១០០.០០០រៀលទៅ ៥០០.០០០រៀល (២៥ ទៅ ១២២ដុល្លារអាមេរិក)។ ប៉ុន្តែ មិនមានការចាប់ខ្លួន ឬកាត់ទោសឡើយ។ រដ្ឋាភិបាលធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈដែលផ្តោតជាក់លាក់លើស្ត្រីលក់ស្រាបៀរនៅកន្លែងកម្សាន្តដែលបានរាយការណ៍ថា ងាយរងគ្រោះថ្នាក់ដោយសារការបៀតបៀន។ ពុំទាន់មានព័ត៌មានអំពីអត្រានៃការកើតមានបទល្មើសនេះនៅឡើយទេ។

<u>សិទ្ធិបន្តពូជ៖</u> គូស្វាមីភរិយា និងបុគ្គលម្នាក់ៗអាចសម្រេចចិត្តចំពោះចំនួនកូនដែលចង់បាន គម្លាតមានកូន និងរយៈពេលមានកូន ហើយពួកគេមានព័ត៌មាន និងមធ្យោបាយដើម្បីធ្វើការសម្រេចចិត្តដោយសេរីដោយគ្មានការរើសអើង។ ស្ត្រីមានសិទ្ធិទទួលសេវាពន្យារកំណើត និងការថែទាំមុនពេលសម្រាល ព្រមទាំងឆ្មបមានជំនាញ និងការថែទាំក្រោយពេលសម្រាលផងដែរ ប៉ុន្តែជារឿយៗ សិទ្ធនេះនៅមានកម្រិត ដោយសារឧបសគ្គប្រាក់ចំណូល និងភូមិសាស្ត្រ។ យោងតាមការអង្កេតសុខភាពប្រជាសាស្ត្រប្រទេសកម្ពុជា អត្រាមរណៈមាតានៅឆ្នាំ២០១០ មានចំនួន ២០៦នាក់ក្នុងទារកកើតរស់ចំនួន ១០០.០០០នាក់។ កត្តាចម្បង ដែលមានឥទ្ធិពលលើអត្រាមរណៈមាតាខ្ពស់នៅក្នុងប្រទេសរួមមាន កង្វះមណ្ឌលសុខភាពត្រឹមត្រូវ ថ្នាំសង្កូវ និងឆ្មបមានជំនាញត្រឹមត្រូវ។

<u>ការរើសអើង៖</u> រដ្ឋធម្មនុញ្ញចែងអំពីសិទ្ធិស្មើភាពគ្នាចំពោះស្ត្រី ការទទួលបានប្រាក់កម្រៃស្មើគ្នាចំពោះការងារដូចគ្នា និងស្ថានភាពស្មើគ្នាចំពោះការរៀបការ។ ជាទូទៅ ស្ត្រីមានសិទ្ធិលើទ្រព្យសម្បត្តិស្មើភាពគ្នា មានសិទ្ធិផ្លូវច្បាប់ដូចគ្នាក្នុងការដាក់ពាក្យបណ្តឹងលែងលះ និងសិទ្ធិទទួលបានការអប់រំស្មើគ្នា និងការងារមួយចំនួន។ ប៉ុន្តែប្រពៃណីវប្បធម៌បានកម្រិតសមត្ថភាពរបស់ស្ត្រីដើម្បីឈានទៅដល់ការទទួលបានមុខតំណែងជាន់ខ្ពស់នៅក្នុងការងារ និងផ្នែកផ្សេងទៀត។ ជារឿយៗ ស្ត្រីត្រូវបានប្រមូលផ្តុំនៅក្នុងការងារដែលទទួលបានប្រាក់កម្រៃទាប និងភាគច្រើនត្រូវបានដកចេញពីមុខតំណែងផ្នែកគ្រប់គ្រង។ បុរសយ៉ាងច្រើនសន្ធឹកសន្ធាប់បម្រើការងារយោធា នគរបាល និងសេវាសាធារណៈ។

ក្រសួងកិច្ចការនារី ដែលត្រូវបានផ្តល់អាណត្តិដើម្បីការពារសិទ្ធិស្ត្រី និងលើកកម្ពស់សមភាពយេនឌ័រនៅក្នុងសង្គម បានបន្តកម្មវិធី នារីរតនៈ ("ស្ត្រីជាត្បូងពេជ្រដ៏មានតម្លៃ")។ កម្មវិធីនេះមានគោលបំណងលើកកម្ពស់ មុខមាត់ស្ត្រីតាមរយៈការបញ្ជ្រាបយេនឌ័រ ជំរុញឱ្យស្ត្រីចូលរួមនៅក្នុងជីវិតសេដ្ឋកិច្ច និងនយោបាយ និងការការពារសិទ្ធិស្ត្រី។ ក្រសួងរដ្ឋាភិបាលចំនួន ១៦ បានបន្តផែនការសកម្មភាពបញ្ជ្រាបយេនឌ័រដោយមាន ការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងកិច្ចការនារី។

## កុមារ

<u>ការចុះបញ្ជីកំណើត៖</u> តាមច្បាប់ ភាពជាពលរដ្ឋអាចទទួលបានតាមរយៈកំណើតពីឪពុកម្តាយដែលមិនមែន ជាជនជាតិខ្មែរ ក្នុងករណីដែលឪពុកម្តាយទាំងពីរនោះបានកើត និងរស់នៅដោយស្របច្បាប់នៅក្នុងប្រទេសកម្ពុជា ឬករណីដែលឪពុក/ម្តាយណាម្នាក់ទទួលបានសញ្ជាតិកម្ពុជា។ ជនជាតិខ្មែរត្រូវបានចាត់ទុកជាពលរដ្ឋខ្មែរ។ ក្រសួងមហាផ្ទៃបានគ្រប់គ្រងប្រព័ន្ធចុះបញ្ជីកំណើតតាមបែបទំនើប ប៉ុន្តែ ទារកទាំងអស់មិនសុទ្ធតែត្រូវបានចុះបញ្ជីភ្លាមៗឡើយ ដោយតែឪពុកម្តាយពន្យារពេល។ ប្រព័ន្ធនេះមិនបានដាក់បញ្ចូលសេវាពិសេស នេះទៅក្នុងសហគមន៍ភាគតិចឡើយ។ ក្រៅពីនេះ ទារកដែលបានកើតចាប់ពីពាក់កណ្តាលទស្សវត្សរ៍ឆ្នាំ១៩៧០ ដល់ពាក់កណ្តាលទស្សវត្សរ៍ឆ្នាំ១៩៩០ ជាទូទៅ មិនត្រូវបានចុះបញ្ជីកំណើតឡើយ ដោយសារការគ្រប់គ្រងរបស់វៀតណាម/ខ្មែរក្រហម/សង្គ្រាមស៊ីវិល។ អ្នកដែលមិនបានចុះបញ្ជីទាំងនេះជាច្រើន ដែលក្រោយមកមាន គ្រួសារផ្ទាល់ខ្លួន មិនបានយល់អំពីភាពចាំបាច់នៃការចុះបញ្ជីនេះទេ។ ជាទូទៅ យុវជនមិនទៅចុះបញ្ជី កំណើតឡើយ ប្រសិនបើគ្មានភាពចាំបាច់នោះ។ ការខកខានមិនបានចុះបញ្ជីទារកទាំងអស់នាំឱ្យមានការ រើសអើង ដែលរួមមានការបដិសេធមិនផ្តល់សេវាសាធារណៈជាដើម។ ការសិក្សាមួយដែលធ្វើឡើងដោយអង្គការ UNHCR ស្តីពីភាពគ្មានសញ្ជាតិនៅក្នុងប្រទេសកម្ពុជាបានថ្លែងថា ជារឿយៗ កុមារជនជាតិភាគតិច និងកុមារដែលគ្មានសញ្ជាតិត្រូវបានផាត់ចេញពីដំណើរការចុះបញ្ជីកំណើត។ អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាចំពោះសហគមន៍ដែលបានគេផាត់ចេញបានរាយការណ៍ថា ជារឿយៗ កុមារដែលមិនមានសំបុត្រកំណើត និងសៀវភៅគ្រួសារបាត់បង់លទ្ធភាពទទួលបានការអប់រំ និងការថែទាំសុខភាព។ អង្គការមិនមែនរដ្ឋាភិបាលទាំងនោះក៏បានបញ្ជាក់ផងដែរថា ទៅថ្ងៃអនាគត កុមារទាំងនេះអាចមិនមានលទ្ធភាពទទួលបានការងារធ្វើ មានទ្រព្យសម្បត្តិផ្ទាល់ខ្លួន ចូលរួមបោះឆ្នោត ឬប្រើប្រាស់ប្រព័ន្ធច្បាប់នោះទេ។

<u>ការអប់រំ៖</u> កុមារទទួលរងផលប៉ះពាល់ជាអវិជ្ជមាន ដោយសារប្រព័ន្ធអប់រំមិនគ្រប់គ្រាន់។ ការអប់រំ រហូតដល់ថ្នាក់ទី៩ គឺឥតមានបង់ថ្លៃឡើយ ប៉ុន្តែ មិនមែនជាការអប់រំកាតព្វកិច្ចទេ។ កុមារជាច្រើនបានឈប់រៀនដើម្បីជួយគ្រួសារក្នុងការងារកសិកម្មលក្ខណៈគ្រួសារ ធ្វើការងារនៅក្នុងសកម្មភាពផ្សេងទៀត ចូលរៀននៅអាយុច្រើន ឬមិនចូលរៀនសោះតែម្តង។ រដ្ឋាភិបាលមិនបដិសេធក្មេងស្រីក្នុងការទទួលបានការអប់រំស្មើភាពគ្នាទេ។ ប៉ុន្តែ ជារឿយៗ គ្រួសារដែលមានធនធានមានផ្តល់អាទិភាពដល់ក្មេងប្រុសជាងក្មេងស្រី។ យោងតាមរបាយការណ៍អង្គការអន្តរជាតិ បន្ទាប់ពីកម្រិតបឋមសិក្សា ចំនួនក្មេងស្រីចុះឈ្មោះចូលរៀនធ្លាក់ចុះយ៉ាងខ្លាំង។ សាលារៀននៅក្នុងតំបន់ជាច្រើនស្ថិតនៅឆ្ងាយពីផ្ទះ ហើយការធ្វើដំណើរការក៏ជាបញ្ហាមួយផងដែរ។ កត្តានេះបានធ្វើឱ្យប៉ះពាល់ដល់ក្មេងស្រីជាពិសេស ដោយសារកង្វល់ពីសុវត្ថិភាពក្នុងការធ្វើដំណើរពីផ្ទះទៅសាលារៀន។

<u>ការធ្វើបាបកុមារ៖</u> ការធ្វើបាបកុមារត្រូវបានជឿថា មានជាទូទៅ ទោះបីមិនស្ថិតិអំពីរឿងនេះក្តី។ ការរំលោភសេពសន្ថវៈកុមារនៅតែជាបញ្ហាធ្ងន់ធ្ងរមួយនៅឡើយ។ គិតមកត្រឹមខែតុលា អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបានរាយការណ៍ថា ករណីរំលោភសេពសន្ថវៈ និងប៉ុនប៉ងរំលោភសេពសន្ថវៈចំនួន ៣០៤ករណី បានកើតឡើងចំពោះកុមារដែលមានអាយុក្រោម ១៨ឆ្នាំ។ ករណីចំនួន ៣៥ មានពាក់ព័ន្ធជាមួយកុមារអាយុក្រោម ៥ឆ្នាំចំនួន ៧៣ករណី មានពាក់ព័ន្ធជាមួយកុមារអាយុពី ៥ ទៅ ១០ឆ្នាំ ហើយករណីចំនួន ១៩៦ មានពាក់ព័ន្ធជាមួយកុមារអាយុពី ១០ ទៅ ១៨ឆ្នាំ។

ការកេងប្រវ័ញ្ចផ្លូវភេទ៖ ការរួមភេទជាមួយកុមារអាយុក្រោម ១៥ឆ្នាំ គឺជាអំពើខុសច្បាប់។ ប៉ុន្តែ ពេស្យាចារកុមារ និងការជួញដូរកុមារបានកើតឡើង។ នៅអំឡុងពេលឆ្នាំនេះ នគរបាលបានវាយឆ្មក់ចូលផ្ទះបន ពេស្យាចារជាច្រើនកន្លែង និងបានជួយសង្គ្រោះក្មេងស្រីមិនគ្រប់អាយុដែលត្រូវបានគេជួញដូរធ្វើពេស្យាចារ។ ក្រសួងមហាផ្ទៃបានរាយការណ៍ថា គិតមកត្រឹមខែវិច្ឆិកានេះ អាជ្ញាធរបានចាប់ខ្លួនជនបរទេសចំនួន ២១នាក់ ពីបទរួមភេទជាមួយកុមារ។ កុមារមួយចំនួនបានចូលលក់ខ្លួននៅក្នុងបនពេស្យាចារដើម្បីចិញ្ចឹមជីវិត ដោយមិនមានការចូលរួមពីភាគីទីបីណាឡើយ។ រដ្ឋាភិបាលក៏បានប្រើប្រាស់ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ដើម្បីកាត់ទោសអ្នកទេសចរណ៍ផ្លូវភេទដែលរំលោភបំពានដល់កុមារផងដែរ។

ច្បាប់ស្តីពីការជួញដូរមនុស្សដាក់ទោសចំពោះការកេងប្រវ័ញ្ចផ្លូវភេទកុមារជាលក្ខណៈពាណិជ្ជកម្ម ដោយដាក់ពន្ធនាគារចាប់ពី ២ ទៅ ១៥ឆ្នាំ។ ច្បាប់នេះក៏ហាមប្រាមចំពោះរូបអាសអាភាសរបស់កុមារផងដែរ។

កុមារគ្មានទីជម្រក៖ តាមរយៈមជ្ឈមណ្ឌលស្តារនីតិសម្បទា រដ្ឋាភិបាលបានផ្តល់សេវាដល់កុមារតាមចិញ្ចើមថ្នល់ផងដែរ ប៉ុន្តែនៅមានកម្រិត និងមិនគ្រប់គ្រាន់នោះទេ។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយបានវាយតម្លៃថា មានកុមារតាមចិញ្ចើមផ្លូវប្រមាណជា ១.២០០ ទៅ ១.៥០០នាក់នៅក្នុងរាជធានីភ្នំពេញ ដែលមិនមានគ្រួសារ ហើយកុមារប្រមាណជាពី ១៥.០០០ ទៅ ២០.០០០នាក់ បានធ្វើការងារនៅតាមចិញ្ចើមផ្លូវ ប៉ុន្តែ បានត្រឡប់ទៅផ្ទះវិញនៅពេលល្ងាច។ កុមារប្រមាណជា ៥០០ ទៅ ១.៥០០នាក់ បានរស់នៅជាមួយគ្រួសាររបស់ខ្លួននៅតាមចិញ្ចើមផ្លូវនៃរាជធានីភ្នំពេញ។

កុមារក្នុងពន្ធនាគារ៖ ក្រសួងមហាផ្ទៃបានរាយការណ៍ថា យ៉ាងហោចណាស់ កុមារក្រោមអាយុ ៦ឆ្នាំចំនួន ១០៩ នាក់ ត្រូវបានគេរាយការណ៍ថា កំពុងរស់នៅជាមួយម្តាយរបស់ខ្លួននៅក្នុងពន្ធនាគារគិតត្រឹមខែកញ្ញានេះ។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយបានរាយការណ៍ថា មានកុមារចំនួន ៧៣នាក់ ដែលរស់នៅក្នុងពន្ធនាគារចំនួន១៩ គិតត្រឹមខែវិច្ឆិកា និងបានអះអាងថា កុមារទាំងនេះទទួលបានការមើលថែមិនបានល្អពីឆ្មាំពន្ធនាគារ និងប្រឈមមុខនឹងគ្រោះថ្នាក់រាងកាយពីអ្នកទោសព្រហ្មទណ្ឌដែលជាមនុស្សពេញវ័យ។ ជាទូទៅ កុមារទាំងនេះខ្វះអាហារូបត្ថម្ភ និងការអប់រំគ្រប់គ្រាន់។

ការចាប់ជំរិតកុមារឆ្លងដែន៖ ប្រទេសកម្ពុជាមិនមែនជាហត្ថលេខីនៃអនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩៨០ ស្តីពីទិដ្ឋភាពស៊ីវិលនៃការចាប់ជំរិតកុមារឆ្លងដែនឡើយ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលមើលរបាយការណ៍ស្តីពីការអនុវត្តច្បាប់របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក នៅគេហទំព័រ http://travel.state.gov/abduction/resources/congressreport/congresreport_4308.html។

## ការប្រឆាំងនឹងសាសនាជ្វីស (Anti-Semitism)

មានសហគមន៍អនិកជនកាន់សាសនាជ្វីសតូចមួយនៅក្នុងរាជធានីភ្នំពេញ ហើយមិនមានរបាយការណ៍អំពីទង្វើប្រឆាំងនឹងសាសនានេះឡើយ។

## ការជួញដូរមនុស្ស

សូមចូលមើល*របាយការណ៍ស្តីពីការជួញដូរមនុស្ស* របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក នៅគេហទំព័រ www.state.gove/j/tip។

## ជនពិការ

ច្បាប់ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិជនពិការឆ្នាំ២០០៩ ហាមឃាត់ការរើសអើង ការព្រងើយកន្តើយ ឬការបោះបង់ជនពិការ។ នៅក្នុងច្បាប់នេះ និយមន័យជនពិការរួមបញ្ចូលទាំងជនដែលមានជំងឺសតិស្មារតី និងជនពិការប្រាជ្ញាផងដែរ ហើយច្បាប់នេះក៏តម្រូវផងដែរថា អគារសាធារណៈ និងទីតាំងផ្តល់សេវារដ្ឋាភិបាលរួមទាំងគ្រឹះស្ថានអប់រំផងដែរ ត្រូវមានមធ្យោបាយដែលអាចឱ្យជនពិការចេញចូលបាន។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាទទួលខុសត្រូវទាំងស្រុងចំពោះការការពារសិទ្ធិជនពិការ ទោះបីច្បាប់នេះបានចាត់តាំងភារកិច្ចជាក់លាក់ទៅដល់បណ្តាក្រសួងផ្សេងទៀតរួមមាន ក្រសួងសុខាភិបាល ក្រសួងអប់រំ ក្រសួងសាធារណៈការ និងដឹកជញ្ជូន ព្រមទាំងក្រសួងការពារជាតិផងដែរ។ រដ្ឋាភិបាលបានស្នើឱ្យបណ្តាញទូរទស្សន៍ទាំងអស់ប្រើប្រាស់ការបកប្រែភាសាសញ្ញាក្នុងកម្មវិធីរបស់ខ្លួន។ ហើយគិតត្រឹមខែកញ្ញា ស្ថានីយទូរទស្សន៍ចម្បងមួយមានការបកប្រែភាសាសញ្ញា ហើយក្រសួងព័ត៌មានកំពុងធ្វើការងារជាមួយនឹងស្ថានីយទូរទស្សន៍ផ្សេងទៀតដើម្បីអភិវឌ្ឍន៍សមត្ថភាពក្នុងការបកប្រែភាសាសញ្ញានេះ។ រដ្ឋាភិបាលបានបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការអនុវត្តច្បាប់នេះ ទោះបីជារយៈពេលពេញលេញសម្រាប់អនុវត្តច្បាប់នៅក្នុងករណីមួយចំនួនអាចពន្យារដល់ឆ្នាំ២០១៥ ក៏ដោយ។ គិតត្រឹមខែកញ្ញា ទីស្តីការគណៈរដ្ឋមន្ត្រីបានអនុម័តអនុក្រឹត្យចំនួន ៩ ដើម្បីគាំទ្រច្បាប់នេះ។

កម្មវិធីដែលរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាលនានាបានធ្វើការកែលម្អគួរឱ្យកត់សម្គាល់ចំពោះការប្រព្រឹត្ត និងការស្តារនីតិសម្បទាជនពិការ ប៉ុន្តែ ពួកគាត់បានប្រឈមមុខនឹងការរើសអើងពីសង្គម ជាពិសេសលទ្ធភាពក្នុងការទទួលបានការងារជំនាញ។

មិនមានការដាក់កំហិតផ្លូវច្បាប់លើសិទ្ធិជនពិការក្នុងការបោះឆ្នោត ឬចូលរួមនៅក្នុងកិច្ចការស៊ីវិលឡើយ ប៉ុន្តែរដ្ឋាភិបាលមិនបានខិតខំប្រឹងប្រែងសហការណាមួយ ដើម្បីជួយពួកគាត់ឱ្យមានការចូលរួមក្នុងកិច្ចការស៊ីវិលកាន់តែច្រើនឡើយ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាមានទំនួលខុសត្រូវក្នុងការបង្កើតគោលនយោបាយដើម្បីការពារសិទ្ធិ និងស្តារនីតិសម្បទាជនពិការ ក៏ដូចជាផ្តល់ការបណ្តុះបណ្តាលជំនាញការងារសម្រាប់ពួកគាត់។

## សញ្ជាតិ/ពូជសាសន៍/ជនជាតិដើមភាគតិច

ច្បាប់ស្តីពីសញ្ជាតិមិនមានចែងច្បាស់លាស់អំពីសិទ្ធិរបស់ជនជាតិដើមភាគតិចឡើយ។ ការការពារក្នុងធម្មនុញ្ញគ្របដណ្តប់តែ "ប្រជាជនខ្មែរ" ប៉ុណ្ណោះ។ ពលរដ្ឋចិន និងវៀតណាមគឺជាជនជាតិភាគតិចភាគច្រើនបំផុត។ ជនជាតិចិនត្រូវបានទទួលយកនៅក្នុងសង្គម ប៉ុន្តែ មានការបន្តស្អប់ខ្ពើមចំពោះជនជាតិវៀតណាម ដែលត្រូវបានគេមើលឃើញថា ជាការគំរាមកំហែងចំពោះប្រទេសជាតិ និងវប្បធម៌។ ក្រុមមួយចំនួនរួមទាំង ក្រុមនយោបាយបានបន្តធ្វើសេចក្តីថ្លែងប្រឆាំងនឹងជនជាតិវៀតណាមយ៉ាងខ្លាំងក្លា។ ក្រុមទាំងនេះបានស្តីបន្ទោសថា មានការ

កៀបសង្កត់ផ្នែកនយោបាយពីប្រទេសវៀតណាមលើគណបក្សប្រជាជនកម្ពុជា បញ្ហាទន្រ្ទាននៅតាមតំបន់ព្រំដែន និងបញ្ហាជាច្រើនផ្សេងទៀត ដែលក្រុមទាំងនេះបានដាក់កំហុសទៅលើជនជាតិវៀតណាម យ៉ាងហោចណាស់ ដោយផ្នែកផងដែរ។

## ជនជាតិដើមភាគតិច

ជារឿយៗ រដ្ឋាភិបាលមិនយកចិត្តទុកដាក់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងកិច្ចការពារទឹកដីដូនតា និងធនធានធម្មជាតិរបស់ខ្លួននោះទេ។ ទោះបីជាច្បាប់ភូមិបាល ឆ្នាំ២០០១ តម្រូវឱ្យមានការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចក៏ដោយ មានកិច្ចការតិចតួចប៉ុណ្ណោះដែលបានធ្វើឡើងដើម្បីអនុវត្តការផ្តល់ប័ណ្ណកម្មសិទ្ធិដីសហគមន៍។ អង្គការមិនមែនរដ្ឋាភិបាលបានអំពាវនាវឱ្យមានការពន្យារពេលលក់ដី និងសម្បទានដីដែលប៉ះពាល់ដល់សហគមន៍ជនជាតិដើមភាគតិច។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិមានសកម្មភាពយ៉ាងសកម្មក្នុងការអប់រំសហគមន៍ជនជាតិដើមភាគតិចអំពីដំណើរការចុះបញ្ជីដី ព្រមទាំងផ្តល់ជាតំណាងផ្នែកច្បាប់ក្នុងវិវាទផងដែរ។ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា ការបាត់បង់ដីកសិកម្ម និងរបៀបរស់នៅ ដោយសារការផ្តល់សម្បទានដីសេដ្ឋកិច្ចកើនឡើងនៅលើដីជនជាតិដើមភាគតិច។ គិតត្រឹមខែកញ្ញា សមាជិកសកម្មសិទ្ធិជនជាតិដើមភាគតិចរបស់អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា ខ្លួនបានកត់ត្រាវិវាទដីធ្លីដែលកំពុងបន្តចំនួន ១៩ករណី ដែលពាក់ព័ន្ធជាមួយក្រុមជនជាតិដើមភាគតិច។

## ការរំលោភបំពានក្នុងសង្គម ការរើសអើង ព្រមទាំងសកម្មភាពអំពើហិង្សាដោយហេតុផលផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ

មិនមានច្បាប់ដែលដាក់ទោសព្រហ្មទណ្ឌលើការស្រឡាញ់ភេទដូចគ្នាឡើយ ហើយក៏មិនមានការរើសអើងប្រឆាំងនឹងសហគមន៍ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស បុគ្គលដែលស្រឡាញ់ទាំងបុរស និងស្ត្រី និងអ្នកវះកាត់កែអវយវៈភេទ (LGBT) នោះទេ ទោះបីជានៅតែបន្តមានការរើសអើងពីសង្គមមួយចំនួន និងការវាយតម្លៃជារួមក៏ដោយ ជាពិសេសនៅក្នុងតំបន់ជនបទ។ នៅខែឧសភា ក្រុមហ៊ុនក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានរៀបចំកម្មវិធីមោទនភាពរាជធានីភ្នំពេញប្រចាំឆ្នាំលើកទី៧ ដែលជាព្រឹត្តិការណ៍រយៈពេលពេញមួយសប្តាហ៍ដែលបង្ហាញពីសហគមន៍ LGBT។

មិនមានរបាយការណ៍អំពីការរើសអើងពីសំណាក់រដ្ឋាភិបាលពាក់ព័ន្ធនឹងការតម្រង់ទិសផ្លូវភេទនៅក្នុងការងារ ភាពគ្មានសញ្ជាតិ ឬលទ្ធភាពទទួលបានការអប់រំ ឬការថែទាំសុខភាពឡើយ។ ប៉ុន្តែ អំពើស្រឡាញ់ភេទដូចគ្នា ជាទូទៅ ទទួលរងការខ្លាចរអារ និងសង្ស័យពីសំណាក់ប្រជាជនទូទៅ ហើយមានក្រុមគាំទ្រតិចតួចប៉ុណ្ណោះដែលករណីបែបនេះដែលអាចរាយការណ៍ទៅកាន់ក្រុមគាំទ្រនោះបាន។

មានរបាយការណ៍តិចតួចអំពីក្រុមហ៊ុនឯកជនដែលបដិសេធមិនផ្តល់ការងារ ឬជួលអចលនទ្រព្យឱ្យបុគ្គលដោយផ្អែកលើការតម្រង់ទិសផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័រ។

## អំពើហិង្សា ឬការរើសអើងក្នុងសង្គមផ្សេងទៀត

មិនមានការរើសអើងជាផ្លូវការចំពោះអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ឡើយ។ ការរើសអើងចំពោះអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍នៅក្នុងសង្គមនៅតែជាបញ្ហាតាមតំបន់ជនបទ។ ប៉ុន្តែ តាមរយៈកម្មវិធីយល់ដឹងអំពីមេរោគអេដស៍/ជំងឺអេដស៍ ការរើសអើងនេះមានកម្រិតមធ្យមផងដែរទេ។

## ផ្នែកទី៧៖ សិទ្ធិកម្មករ-និយោជិត

### ក. សេរីភាពចូលរួម និងសិទ្ធិចរចារជាសមូហភាព

ច្បាប់ប្រទេសកម្ពុជាអនុញ្ញាតឱ្យកម្មករ-និយោជិតវិស័យឯកជនបង្កើត និងចូលរួមជាមួយសហជីពកម្មករ-និយោជិតតាមការជ្រើសរើសដោយខ្លួនឯងដោយពុំបាច់មានការអនុញ្ញាតជាមុន។ ច្បាប់ក៏ផ្តល់សិទ្ធិដល់ការធ្វើកូដកម្ម និងចរចាជាសមូហភាពផងដែរ។ ទោះបីជាសហជីពអាចចងសម្ព័ន្ធភាពដោយសេរីក៏ដោយ ច្បាប់មិនបានបញ្ជាក់ច្បាស់លាស់អំពីសិទ្ធិរបស់សហជីពក្នុងការចងសម្ព័ន្ធភាពជាលក្ខណៈអន្តរជាតិនោះទេ។

ច្បាប់តម្រូវឱ្យសហជីពដាក់បញ្ជូនលក្ខន្តិកៈ និងបញ្ជីឈ្មោះថ្នាក់ដឹកនាំសហជីពទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MOLVT)។ ការិយាល័យទំនាក់ទំនងការងារទទួលបន្ទុកសម្របសម្រួលដំណើរការចុះបញ្ជិការសហជីព និងផ្តល់លិខិតបញ្ជាក់ "ភាពជាតំណាងបំផុត" សម្រាប់សហជីព ដែលផ្តល់សិទ្ធិឱ្យសហជីពដែលជាតំណាងកម្មករ-និយោជិតភាគច្រើននៅក្នុងសហគ្រាសណាមួយធ្វើជាតំណាងកម្មករ-និយោជិតទាំងអស់នៅក្នុងសហគ្រាសនោះ។

មន្ត្រីរាជការរួមទាំង គ្រូបង្រៀន ចៅក្រម និងមន្ត្រីយោធា ព្រមទាំងអ្នកបម្រើការងារតាមផ្ទះមិនមានសិទ្ធិ បង្កើត ឬចូលរួមក្នុងសហជីពឡើយ។ បុគ្គលិកនៅក្នុងឧស្សាហកម្មដឹកជញ្ជូនតាមផ្លូវអាកាស និងផ្លូវទឹកមានសេរីភាពក្នុងការបង្កើតសហជីព ប៉ុន្តែ មិនមានសិទ្ធិទទួលបានអត្ថប្រយោជន៍របបសន្តិសុខសង្គម និងប្រាក់សោធននិវត្តន៍ឡើយ ហើយទទួលការលើកលែងពីការកំហិតម៉ោងការងារដែលមានចែងនៅក្នុងច្បាប់។

ច្បាប់ចែងថា កូដកម្មអាចរៀបចំធ្វើបានលុះត្រាតែបំពេញតាមលក្ខខណ្ឌតម្រូវមួយចំនួនសិនដែលរួមមាន ករណីវិធីសាស្ត្រដោះស្រាយវិវាទផ្សេងទៀត (ដូចជា ការចរចា ការផ្សះផ្សារ ឬមជ្ឈត្តកម្ម) បានបរាជ័យ ករណីមានការបោះឆ្នោតសម្ងាត់ពីសមាជិកសហជីព និងត្រូវជូនដំណឹងជាមុនរយៈពេល ៧ថ្ងៃ ដល់និយោជក និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ពុំមានច្បាប់ដែលហាមប្រាមមន្ត្រីរាជការ បុគ្គលិកនៅក្នុងវិស័យសាធារណៈ ឬបុគ្គលិកនៅក្នុងសេវាសំខាន់ៗមិនឱ្យធ្វើកូដកម្មឡើយ។ មានការការពារផ្លូវច្បាប់ដែលការពារកម្មករ-និយោជិតពីការសងសឹក។

បទប្បញ្ញត្តិស្តីពីសិទ្ធិចរចាជាសមូហភាពកំណត់នីតិវិធីដែលចែងថា សហជីពត្រូវបង្ហាញថា ខ្លួនជាតំណាងកម្មករក្នុងន័យចរចាជាសមូហភាព។ បទប្បញ្ញត្តិទាំងនេះផ្តល់សិទ្ធិឱ្យសហជីពចរចាជាសមូហភាពជាមួយនឹងភាពជាតំណាងបំផុត ក៏ដូចជាតម្រូវឱ្យនិយោជកត្រូវធ្វើការចរចា ប្រសិនបើសហជីពស្នើឱ្យមានកិច្ចព្រមព្រៀងអនុសញ្ញារួម។ បទប្បញ្ញត្តិទាំងនេះក៏ចងភ្ជាប់កាតព្វកិច្ចគូភាគីឱ្យឯកភាពនឹងដំណើរការចរចាដែលមានលំដាប់លំដោយត្រឹមត្រូវ និងផ្តល់សំណើ ក៏ដូចជាសំណើតបដែលសមស្រប និងសមហេតុផល ព្រមទាំងតម្រូវឱ្យនិយោជកផ្តល់

ទីតាំង និងព័ត៌មានដែលទាក់ទងនឹងដំណើរការចរចាទាំងអស់ដល់សហជីព តាមការស្នើសុំរបស់សហជីព។ ច្បាប់នេះក៏ផ្តល់ឱ្យមេដឹកនាំសហជីពនូវការការពារបន្ថែមពីការបណ្តេញចេញពីការងារផងដែរ។

វិវាទការងារដែលដោះស្រាយមិនដាច់ស្រេច អាចបញ្ជូនទៅកាន់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលជាអង្គភាពរដ្ឋឯករាជ្យដែលបកស្រាយបទប្បញ្ញត្តិការងារនៅក្នុងករណីវិវាទសមូហភាពដូចជា នៅពេលនិយោជិតជាច្រើនត្រូវបានបណ្តេញចេញពីការងារជាដើម។ គូភាគីអាចជ្រើសរើសសម្រេចថា នឹងទទួលយកសេចក្តីសម្រេច ជាការភ្ជាប់កាតព្វកិច្ចដែរ ឬយ៉ាងណា។ ប្រសិនបើមិនមានភាគីណាមួយដែលជំទាស់ទៅនឹងសេចក្តីសម្រេចទេនោះនៅក្នុងរយៈពេល ៨ថ្ងៃ បន្ទាប់ការចេញសេចក្តីសម្រេច ភាគីត្រូវភ្ជាប់កាតព្វកិច្ចដោយស្វ័យប្រវត្តិ។ វិវាទបុគ្គលអាចយកមកដោះស្រាយនៅចំពោះមុខតុលាការ ទោះបីជាប្រព័ន្ធតុលាការមិនមានភាពអព្យាក្រិត និងតម្លាភាពក៏ដោយ។

ការពង្រឹងការអនុវត្តសិទ្ធិចូលរួមសមាគម និងសេរីភាពរួចផុតពីការរើសអើងប្រឆាំងនឹងសហជីពមានលក្ខណៈមិនស៊ីសង្វាក់គ្នា។ ជារឿយៗ ទង្វើរើសអើងសហជីពពីសំណាក់និយោជកមិនទទួលការដាក់ទណ្ឌកម្មឡើយ។ ពេលខ្លះ កិច្ចការរបស់រដ្ឋាភិបាលក្នុងការពង្រឹងការអនុវត្តសិទ្ធិទាំងនេះត្រូវបន្ទច់បង្អាក់ដោយសារទំនាក់ទំនងជិតស្និទ្ធនៅក្នុងចំណោមមន្ត្រីរដ្ឋាភិបាល និយោជក និងមេដឹកនាំសហជីព។ រដ្ឋាភិបាលក៏មិនផ្តល់ធនធានគ្រប់គ្រាន់ដូចជា អធិការការងារដែលទទួលបានការបណ្តុះបណ្តាល និងមានបទពិសោធន៍ជាដើមចំពោះការពង្រឹងការអនុវត្តនេះផងដែរ។

ការពង្រឹងការអនុវត្តសិទ្ធិចរចាជាសមូហភាពរបស់រដ្ឋាភិបាលមានលក្ខណៈមិនស៊ីសង្វាក់។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានព្រមានជាផ្លូវការដល់ក្រុមហ៊ុនចំនួន ៤០១ក្រុមហ៊ុនពីបទរំលោភច្បាប់បានពិន័យក្រុមហ៊ុនចំនួន ១៧ និងបានប្តឹងក្រុមហ៊ុនចំនួន ៥ ផ្សេងទៀតនៅក្នុងរយៈពេល ១១ខែដំបូងនៃឆ្នាំនេះ។ ទោះបីជាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជារឿយៗ បានសម្រេចដោយឈរលើផលប្រយោជន៍របស់និយោជិតក៏ដោយ ក៏ខ្លួនកម្របានប្រើប្រាស់សិទ្ធិអំណាចស្របច្បាប់របស់ខ្លួនដើម្បីដាក់ ពិន័យដល់និយោជកដែលបដិសេធអនុត្តបទបញ្ជារបស់ក្រសួងណាស់។ ក្រៅពីនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជូនវិវាទដែលដោះស្រាយមិនដាច់ស្រេចចំនួន ១០៥ករណីទៅកាន់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ សហជីពមួយចំនួនបានជំរុញឱ្យរដ្ឋាភិបាលពង្រីកតួនាទីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដោយរួមបញ្ចូលករណីវិវាទផលប្រយោជន៍បុគ្គល និងសមូហភាព ព្រមទាំងធ្វើឱ្យមានការភ្ជាប់កាតព្វកិច្ច ជាមួយនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាផងដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលសំណុំរឿងចំនួន ១៥៥ នៅទូទៅទាំងប្រទេសដែលនៅក្នុងចំណោមនោះប្រហែលជា ៦៧ភាគរយទទួលបានការដោះស្រាយប្រកបដោយជោគជ័យ។

សហជីពភាគច្រើនមានសម្ព័ន្ធភាពជាមួយគណបក្សកាន់អំណាច។ ចំណែកសហជីពផ្សេងទៀតជាសហជីពឯករាជ្យ។ មេដឹកនាំសហជីពដែលមកពីវិសាលគមនយោបាយបានតវ៉ាថា សហព័ន្ធសហជីពយុវជនខ្មែរដែលគាំទ្ររដ្ឋាភិបាលបានគំរាមកំហែង និងបៀតបៀនជាទម្លាប់ទៅលើកម្មករ-និយោជិតមកពីសហជីពផ្សេងទៀត។

ការរៀបចំបង្កើតសហជីព ឬសមាគមនៅក្នុងចំណោមបុគ្គលិកវិស័យសាធារណៈបានប្រឈមមុខនឹងឧបសគ្គជាច្រើន។ សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជាបានចុះបញ្ជិការជា "សមាគម" ដោយសារការហាមឃាត់លើសហជីពវិស័យសាធារណៈ ហើយជារឿយៗ រដ្ឋាភិបាលបានបដិសេធសំណើសុំការអនុញ្ញាតដង្ហែរក្បួន និងធ្វើ

ការតវ៉ា ទោះបីជាសហជីពបានរាយការណ៍ថា មិនមានការជ្រៀតជ្រែកដោយផ្ទាល់ណាមួយពីរដ្ឋាភិបាលចំពោះសកម្មភាពប្រចាំថ្ងៃរបស់ខ្លួននោះទេ។ សមាជិកមួយចំនួនភ័យខ្លាចថា សម្ព័ន្ធភាពរបស់ខ្លួនជាមួយនឹងសមាគមអាចបន្ទច់បង្អាច់ឱកាសអភិវឌ្ឍការងាររបស់ខ្លួន។ សមាគមវិស័យសាធារណៈមួយផ្សេងទៀតគឺ សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា បានលើកឡើងថា ការភ័យខ្លាចការបៀតបៀន ការរើសអើង ឬបញ្ចុះតំណែងជាកត្តាដែលរារាំងបុគ្គលមិនឱ្យចូលរួមក្នុងសមាគម។

រដ្ឋាភិបាលបានអនុញ្ញាតឱ្យកូដកម្មភាគច្រើនអាចធ្វើឡើងនៅរោងចក្រ ប៉ុន្តែ បានបដិសេធការស្នើសុំរបស់កម្មករក្នុងការរៀបចំក្បួនដង្ហែរបាតុកម្មនៅក្រៅទីតាំងរោងចក្រ។

មានរបាយការណ៍គួរជឿទុកចិត្តដែលបានបង្ហាញថា មានការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងសហជីពពីសំណាក់និយោជក រួមទាំងការបណ្តេញមេដឹកនាំសហជីពក្នុងរោងចក្រកាត់ដេរ និងសហគ្រាសផ្សេងទៀតចេញការងារផងដែរ។ មេដឹកនាំសហជីពប្រមាណជា ៥០នាក់បានអះអាងថា ខ្លួនត្រូវបានថៅកែបណ្តេញចេញពីការងារ ឬព្យួរការងារដោយមិនមានមូលហេតុនៅអំឡុងឆ្នាំនេះ។ នៅក្នុងរោងចក្រមួយចំនួន ថ្នាក់គ្រប់គ្រងទំនងជាបានបង្កើត ឬគាំទ្រសហជីពដែលគាំទ្រថ្នាក់គ្រប់គ្រង ឬបន្ថយឥទ្ធិពលមេដឹកនាំសហជីពដោយបង្កបញ្ហាដល់ការងាររបស់ពួកគេ។

ទោះបីជាបទប្បញ្ញត្តិច្បាប់ការពារកូដករពីការសងសឹកក៏ដោយ ក៏មានរបាយការណ៍គួរជឿទុកចិត្តដែលបានបង្ហាញថា កម្មករ-និយោជិតត្រូវបានបណ្តេញចេញពីការងារដោយឈរលើមូលដ្ឋានមិនពិត បន្ទាប់ពីពួកគេរៀបចំ ឬចូលរួមនៅក្នុងកូដកម្ម។ ទោះបីជាកូដកម្មភាគច្រើនមិនស្របច្បាប់ក៏ដោយ ការចូលរួមនៅក្នុងកូដកម្មមិនស្របច្បាប់មិនមែនជាហេតុផលដែលអាចទទួលយកបានដោយស្របច្បាប់ចំពោះការបណ្តេញកម្មករ-និយោជិតចេញពីការងារឡើយ។ នៅក្នុងករណីភាគច្រើន និយោជកបានដាក់សម្ពាធដល់កូដករឱ្យទទួលយកសំណង និងឈប់ពីការងាររបស់ខ្លួន។

មានដំណោះស្រាយសក្តានុពលសម្រាប់បញ្ហាការបណ្តេញចេញពីការងារនេះ ទោះបីជាមិនមានដំណោះស្រាយណាមួយដែលមានប្រសិទ្ធភាពខ្ពស់ជាងគេក៏ដោយ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈអាចចេញបទបញ្ជាឱ្យប្រគល់ការងារទៅឱ្យកម្មករ-និយោជិតវិញបាន ប៉ុន្តែជារឿយៗ បទបញ្ជាទាំងនេះ បានបង្កឱ្យមានជាការដាក់សម្ពាធពីថ្នាក់គ្រប់គ្រងឱ្យកម្មករលាឈប់ពីការងារជាថ្នូរទៅនឹងដំណោះស្រាយទៅវិញ។

### ខ. ការហាមឃាត់ការងារដោយបង្ខំ ឬជាកាតព្វកិច្ច

ច្បាប់នេះហាមឃាត់ចំពោះការងារដោយបង្ខំ ឬជាកាតព្វកិច្ច ប៉ុន្តែ មានការរាយការណ៍ថា ការអនុវត្តបែបនេះបានកើតឡើងនៅក្នុងការងារតាមផ្ទះ និងនៅក្នុងវិស័យក្រៅផ្លូវការ។ កុមារនៅក្នុងគ្រួសារក្រីក្រនៅតែ ប្រឈមនឹងហានិភ័យ ដោយសារពេលខ្លះ គ្រួសារអ្នកមានបានបោកបញ្ឆោតលួងលោមដោយនិយាយថា ជួលពួកគាត់ឱ្យធ្វើជាអ្នកបម្រើតាមផ្ទះ ប៉ុន្តែគោលបំណងគឺដើម្បីរំលោភបំពាន និងកេងប្រវ័ញ្ចពួកគាត់។ មន្ត្រីរដ្ឋាភិបាលបានរាយការណ៍ថា ការផ្ទៀតផ្ទាត់លក្ខខណ្ឌការងារ និងប្រាក់បៀវត្សរ៍របស់អ្នកបម្រើតាមផ្ទះ នៅតែមានការលំបាកដោយសារតែលក្ខណៈក្រៅផ្លូវការនៃការងារនេះ។

សូមចូលមើល*របាយការណ៍ស្តីពីការជួញដូរមនុស្ស* របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក នៅគេហទំព័រ www.state.gove/j/tip។

## គ. ការហាមឃាត់ចំពោះពលកម្មកុមារ និងអាយុធ្វើការងារអប្បបរមា

ច្បាប់កំណត់ថា អាយុធ្វើការងារអប្បបរមាគឺ ១៥ឆ្នាំ ហើយសម្រាប់ការងារដែលមានគ្រោះថ្នាក់ អាយុអប្បបរមានេះគឺ ១៨ឆ្នាំ។ ច្បាប់អនុញ្ញាតឱ្យកុមារអាយុចន្លោះពី ១២ ទៅ ១៥ឆ្នាំ ចូលរួមក្នុង "ការងារស្រាល" ដែលជាការងារមិនមានគ្រោះថ្នាក់ដល់សុខភាពរបស់កុមារទាំងនោះ ក៏ដូចជាមិនប៉ះពាល់ដល់ការសិក្សា។ ច្បាប់កំណត់ថា ម៉ោងការងាររបស់កុមារអាយុ ១២ ទៅ ១៥ឆ្នាំ មិនអាចលើសពី ៤ម៉ោងក្នុងមួយថ្ងៃឡើយ សម្រាប់ថ្ងៃសិក្សា និង ៧ម៉ោងក្នុងមួយថ្ងៃ សម្រាប់ថ្ងៃឈប់សម្រាក ក៏ដូចជាហាមឃាត់ការធ្វើការនៅចន្លោះពីម៉ោង ៨:០០ល្ងាច ដល់ម៉ោង ៦:០០ព្រឹក។ រដ្ឋាភិបាលក៏ហាមឃាត់ការទទួលកុមារឱ្យបម្រើការងារនៅក្នុងវិស័យ ដែលមានហានិភ័យចម្បងដល់សុវត្ថិភាព ឬហានិភ័យសុខភាពចំពោះអនីតិជនទាំងនោះ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទទួលបន្ទុកអធិការកិច្ចពលកម្មកុមារទាំងក្នុងវិស័យសេដ្ឋកិច្ចផ្លូវការ និងក្រៅផ្លូវការ ប៉ុន្តែ អធិការការងាររបស់ក្រសួងនេះមិនបានធ្វើអធិការកិច្ចក្នុងវិស័យសេដ្ឋកិច្ចក្រៅផ្លូវការ ក៏ដូចជាមិនបានពង្រឹងការអនុវត្តច្បាប់នៅក្នុងឧស្សាហកម្មខុសច្បាប់ដូចជា រោងចក្រកាត់ដេរដែលមិនចុះបញ្ជិការ និងបើកដំណើរការដោយមិនមានអាជ្ញាប័ណ្ណពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងពាណិជ្ជកម្មជាដើម។ នៅក្នុងវិស័យសេដ្ឋកិច្ចផ្លូវការ អធិការការងារបានធ្វើការពិនិត្យជាប្រចាំចំពោះឧស្សាហកម្មមួយចំនួនដូចជា វិស័យកាត់ដេរ (ដែលមានបញ្ហាពលកម្មកុមារតិចតួចប៉ុណ្ណោះ) ប៉ុន្តែ នៅក្នុងឧស្សាហកម្មមួយចំនួនទៀតដែលមានហានិភ័យពលកម្មកុមារខ្ពស់បំផុត ការធ្វើអធិការកិច្ចការងារ កើតឡើងតែក្នុងករណីដែលមានពាក្យបណ្តឹងប៉ុណ្ណោះ។ មានអធិការការងារចំនួន ១២នាក់នៅក្នុង រាជធានីភ្នំពេញ និង ២៧នាក់ នៅថ្នាក់ក្រុង និងខេត្តដែលទទួលបន្ទុកបញ្ហាពលកម្មកុមារ។ អធិការការងារទាំងនេះមិនមានលក្ខណៈគ្រប់គ្រាន់ក្នុងការពង្រឹងការអនុវត្តច្បាប់ដែលពាក់ព័ន្ធឡើយ។ ច្បាប់ក៏ចែងអំពីការដាក់ពិន័យ ចំនួនពី ៣១ ទៅ ៦០ដង នៃប្រាក់ឈ្នួលប្រចាំខែចំពោះចុងចោទដែលត្រូវបានចោទប្រកាន់ពីបទរំលោភលើបទប្បញ្ញត្តិពលកម្មកុមារផងដែរ។

នៅថ្ងៃទី០៨ ខែតុលា នគរបាលមកពីនាយកដ្ឋានប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានវាយឆ្មក់ចូលក្រុមហ៊ុន T&P ដែលជាទីភ្នាក់ងារជ្រើសរើសពលករនៅក្នុងខេត្តកំពុងឆ្នាំង។ ការវាយឆ្មក់នេះរកឃើញកម្មករមិនទាន់គ្រប់អាយុធ្វើការចំនួន ៣៥នាក់ ហើយការប្រតិបត្តិការវាយឆ្មក់នេះឈានទៅដល់ការចាប់ខ្លួនមនុស្ស ៤នាក់ និងបញ្ជូនទៅឃុំខ្លួននៅមុនពេលជម្រះក្តី។ នៅថ្ងៃទី១៤ ខែវិច្ឆិកា ក្រសួងមហាផ្ទៃបានស្នើសុំឱ្យក្រសួងការងារ ដកហូតអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុននេះ។

ពលកម្មកុមារកើតឡើងនៅពាសពេញវិស័យកសិកម្ម សិប្បកម្មផលិតឥដ្ឋ ការដ្ឋានផលិតអំបិល សិប្បកម្មកែច្នៃបង្គារ វិស័យនេសាទ ការងារតាមផ្ទះ និងផលិតកម្មកៅស៊ូ។ ពលកម្មកុមារក៏ត្រូវបានគេរាយការណ៍ថាមានកើតឡើងនៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ និងស្បែកជើង ក៏ដូចជាវិស័យបដិសណ្ឋារកិច្ចផងដែរ ប៉ុន្តែមានកម្រិតទាប។ យោងតាមការសិក្សាឆ្នាំ២០០៦ ដែលធ្វើឡើងដោយធនាគារពិភពលោក និងប្រភពផ្សេងទៀត កុមារសកម្មការងារផ្នែកសេដ្ឋកិច្ចលើសពី ៧៥០.០០០នាក់ មានអាយុក្រោម ១២ឆ្នាំ ដែលជា អាយុធ្វើការងារអប្បបរមា។ មានកុមារចំនួន ៥០០.០០០នាក់ បន្ថែមទៀត (អាយុ ១២ ទៅ ១៤ឆ្នាំ) ដែលកំពុងធ្វើការងារ

ពេលយប់ ដែលកម្រិតអាយុនេះស្ថិតក្រោមអាយុអប្បបរមាសម្រាប់ការងារប្រភេទនេះ។ យោងតាមរបាយការណ៍នេះ មានកុមារលើសពី ២៥០.០០០នាក់ អាយុចាប់ពី១៥ ទៅ ១៧ឆ្នាំ ដែលបានធ្វើការលើសពី ៤៣ម៉ោងក្នុងមួយសប្តាហ៍ ឬបានធ្វើការនៅក្នុងវិស័យមានគ្រោះថ្នាក់។ កុមារសកម្មផ្នែកសេដ្ឋកិច្ចចំនួន ៣ ភាគ ៤ កំពុងធ្វើការងារនៅក្នុងវិស័យកសិកម្ម ១៥ភាគរយនៅក្នុងវិស័យពាណិជ្ជកម្ម ៥ភាគរយនៅក្នុងផលិតកម្មខ្នាតតូច និង ២ភាគរយនៅក្នុងសេវាកម្ម។ ការសិក្សាមួយនៅឆ្នាំ២០០៧ អំពីអ្នកបម្រើតាមផ្ទះជាកុមារបានរកឃើញថា ជាទូទៅ កុមារទាំងនេះខកខានមិនបានចូលរៀន ត្រូវធ្វើការងារច្រើនម៉ោងដោយមិនទទួលអត្ថប្រយោជន៍ផ្នែកវេជ្ជសាស្ត្រ និងទទួលបានប្រាក់កម្រៃតិចតួច ឬមិនបានតែម្តង។

សូមចូលមើល*របកគំហើញស្តីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ* របស់ក្រសួងការងារសហរដ្ឋអាមេរិក នៅគេហទំព័រ www.dol.gov/ilab/programs/ocft/tda.htm។

## ឃ. លក្ខខណ្ឌការងារដែលអាចទទួលយកបាន

ច្បាប់តម្រូវឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកំណត់ប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យកាត់ដេរដោយផ្អែកលើអនុសាសន៍ពីគណៈកម្មាធិការប្រឹក្សាការងារ។ នៅដំណាច់ឆ្នាំ ប្រាក់ឈ្នួលប្រចាំខែអប្បបរមាមានចំនួន ២៤៥.០០០រៀល (ប្រហែលជា ៦១ដុល្លារអាមេរិក)។ ច្បាប់នេះមិនកំណត់អាណត្តិប្រាក់ឈ្នួលអប្បបរមាសម្រាប់វិស័យផ្សេងទៀតឡើយ។ ធនាគារពិភពលោកកំណត់ប្រាក់ចំណូលត្រឹម ៥.០០០រៀល (១,២២ដុល្លារអាមេរិក) ក្នុងមួយថ្ងៃជាកម្រិតខ្សែបន្ទាត់ភាពក្រីក្រ។

ច្បាប់ចែងថា ស្តង់ដារការងារស្របច្បាប់ក្នុងមួយសប្តាហ៍គឺ ៤៨ម៉ោង និងមិនឱ្យលើសពី ៨ម៉ោងក្នុងមួយថ្ងៃនោះទេ។ ច្បាប់ក៏កំណត់ផងដែរថា ការងារវេនយប់ទទួលបានអត្រាប្រាក់ឈ្នួលស្មើនឹង ១៣០ភាគរយនៃប្រាក់ឈ្នួលសម្រាប់ការងារពេលថ្ងៃ ហើយ ១៥០ភាគរយ សម្រាប់ការងារថែមម៉ោង ដែលកើនឡើងដល់ ២០០ភាគរយ ប្រសិនបើការងារថែមម៉ោងធ្វើឡើងនៅពេលឈប់ នៅថ្ងៃអាទិត្យ ឬនៅថ្ងៃឈប់សម្រាកបុណ្យជាតិ។ កម្មករ-និយោជិតអាចធ្វើការថែមម៉ោងចំនួន ២ម៉ោងក្នុងមួយថ្ងៃ។ ច្បាប់ហាមឃាត់ការងារថែមម៉ោងច្រើនហួសហេតុ និងចែងថា ការងារថែមម៉ោងទាំងអស់ត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត ហើយក៏ចែងទៀតថាត្រូវបើកប្រាក់សម្រាប់ថ្ងៃឈប់សម្រាកបុណ្យជាតិប្រចាំឆ្នាំផងដែរ។

ច្បាប់ចែងថា កន្លែងធ្វើការគួរមានស្តង់ដារសុខភាព និងសុវត្ថិភាពគ្រប់គ្រាន់ដើម្បីផ្តល់សុខុមាលភាពដល់កម្មករ-និយោជិត។ ច្បាប់មានចែងអំពីការពិន័យដែរ ប៉ុន្តែ មិនមានបទប្បញ្ញត្តិជាក់លាក់ដើម្បីការពារកម្មករ-និយោជិតដែលតវ៉ាអំពីលក្ខខណ្ឌមិនមានសុវត្ថិភាព ឬប៉ះពាល់ដល់សុខភាពឡើយ។ កម្មករ-និយោជិតមានសិទ្ធិចាកចេញពីស្ថានភាពដែលបង្កគ្រោះថ្នាក់ដល់សុខភាព ឬសុវត្ថិភាពនេះបាន។

រដ្ឋាភិបាលមិនបានពង្រឹងការអនុវត្តស្តង់ដារពាក់ព័ន្ធនឹងសំណងម៉ោងការងារ និងសំណងការងារថែមម៉ោងឱ្យមានប្រសិទ្ធភាពឡើយ។ កម្មករ-និយោជិតបានរាយការណ៍ថា ជារឿយៗ ការងារថែមម៉ោងមានចំនួនលើសលុបពេក ហើយពេលខ្លះជាការតម្រូវឱ្យធ្វើតែម្តង។ នៅក្រៅពីឧស្សាហកម្មកាត់ដេរ បទប្បញ្ញត្តិ ស្តីពីម៉ោងការងារ កម្រត្រូវបានអនុវត្តណាស់។ ការងារថែមម៉ោងមិនស្ម័គ្រចិត្តនៅតែជាបញ្ហាមួយ ទោះបីជា ការអនុវត្តបានថយចុះនៅអំឡុងឆ្នាំនេះក៏ដោយ។ និយោជកបានបង្ខិតបង្ខំឱ្យនិយោជិតធ្វើការងារ។ ជារឿយៗ បុគ្គលិក

បានប្រឈមមុខនឹងការពិន័យ ការបណ្តេញចេញពីការងារ ឬការបាត់បង់ប្រាក់ឧបត្ថម្ភ ប្រសិនបើពួកគេបដិសេធមិនធ្វើការងារថែមម៉ោងទេនោះ។

រដ្ឋាភិបាលបានពង្រឹងការអនុវត្តស្តង់ដារដែលមានស្រាប់តាមជម្រើស ដែលហេតុផលមួយគឺដោយសារខ្វះបុគ្គលិកដែលមានការបណ្តុះបណ្តាល និងខ្វះឧបករណ៍។ នាយកដ្ឋានអធិការកិច្ចការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈគឺជាទីភ្នាក់ងារពង្រឹងការអនុវត្តដ៏ចម្បងមួយ ហើយនៅអំឡុងឆ្នាំនេះ ទីភ្នាក់ងារបានចេញការព្រមានដល់ក្រុមហ៊ុនចំនួន ៥០៩ក្រុមហ៊ុន អំពីការរំលោភលើច្បាប់ស្តីពីការងារ។ អធិការការងារចំនួន ១០៧នាក់របស់ទីភ្នាក់ងារនេះបានចុះធ្វើអធិការកិច្ច ប៉ុន្តែ ស្ថានភាពអំពើពុករលួយ និងការដាក់ពិន័យមិនគ្រប់គ្រាន់បានបន្ទចបង្អាក់ដល់ប្រសិទ្ធភាពការងារនេះ។

ទោះបីជាកម្មករ-និយោជិតមានសិទ្ធិដើម្បីចាកចេញពីស្ថានភាពគ្រោះថ្នាក់ក៏ដោយ ក៏ពេលខ្លះ កម្មករដែលធ្វើបែបនេះប្រឈមនឹងហានិភ័យបាត់បង់ការងាររបស់ខ្លួន។ របួស និងបញ្ហាសុខភាពពាក់ព័ន្ធនឹងការបំពេញការងារកើតមានជាទូទៅ។ រោងចក្រកាត់ដេរធំៗភាគច្រើនដែលផលិតសម្រាប់ទីផ្សារនៅក្នុងប្រទេសអភិវឌ្ឍន៍បានបំពេញតាមស្តង់ដារសុខភាព និងសុវត្ថិភាពបានខ្ពស់គួរសម ដោយសារតែជាលក្ខខណ្ឌកិច្ចសន្យារបស់ខ្លួនជាមួយអ្នកទិញ។ ចំណែកឯលក្ខខណ្ឌការងារនៅក្នុងរោងចក្រខ្នាតតូច និងរោងចក្រកប្បាសវិញ មានលក្ខខណ្ឌមិនល្អទេ ហើយជារឿយៗ មិនបានបំពេញស្តង់ដារអន្តរជាតិឡើយ។ មាន ១២.២០៥ ករណីដែលពាក់ព័ន្ធនឹងរបួសពេលកំពុងបំពេញការងារ និង ៥៩ករណី ដែលពាក់ព័ន្ធនឹងការស្លាប់ពេលបំពេញការងារនៅអំឡុងឆ្នាំនេះ។

នៅថ្ងៃទី០៩ និងទី១០ ខែមេសា កម្មករ-និយោជិកប្រមាណជា ៥០០នាក់បានដួលសន្លប់នៅរោងចក្រស្បែកជើង Huey Chuen ក្នុងរាជធានីភ្នំពេញ។ ប្រធានកម្មវិធីការងាររបស់មជ្ឈមណ្ឌលអប់រំច្បាប់សហគមន៍បានលើកឡើងថា បណ្តាកម្មករ-និយោជិតសង្ស័យថា ទឹកពុល ឬក្លិនពុលអាចជាមូលហេតុដែលបង្កឱ្យមានការដួលសន្លប់នេះ។ សភាពភ័យស្លន់ស្លោរ អាហារូបត្ថម្ភមិនគ្រប់គ្រាន់ និងផ្សែងក៏ត្រូវបានគេសង្ស័យថាជាមូលហេតុនៃ ការដួលសន្លប់នេះដែរ។ នៅថ្ងៃទី១១ ខែមេសា ប្រធានសហជីពសេរីកម្មករ-និយោជិតបានអំពាវនាវដល់រដ្ឋាភិបាល ឱ្យធ្វើការស៊ើបអង្កេតករណីនេះ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានរៀបចំសិក្ខាសាលាដែល មានរយៈពេល ៣ថ្ងៃ ជាមួយនឹងតំណាងមកពីវិស័យឧស្សាហកម្មនានាដើម្បីពិភាក្សាអំពីមូលហេតុ និងដំណោះស្រាយដែលអាចមាន។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈអនុវត្តបេឡាឬបសន្តិសុខសង្គមដើម្បីផ្តល់ការថែទាំសុខភាពដល់កម្មករ-និយោជិត។

នៅថ្ងៃទី០៥ ខែធ្នូ រដ្ឋាភិបាលបានបង្កើតយុទ្ធសាស្ត្រជាតិគាំពារសង្គម (NSPS) សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ដែលគ្រោងថានឹងនៅតែមានសុពលភាពរហូតដល់ឆ្នាំ២០១៥។ យុទ្ធសាស្ត្រជាតិគាំពារសង្គមនេះមានទស្សនវិស័យសម្រេចឲ្យបាននូវ "ប្រព័ន្ធជាតិគាំពារសង្គមដ៏មានប្រសិទ្ធភាព តម្លៃសមស្រប និងប្រកបដោយនិរន្តរភាព" ដោយមានការរៀបចំកម្មវិធីមួយចំនួនសំដៅបញ្ចប់នូវភាពក្រីក្ររាំរ៉ៃ ភាពអត់ឃ្លាន និងភាពគ្មានការងារធ្វើ។ រដ្ឋាភិបាលបានប្តេជ្ញាកាត់បន្ថយអត្រាភាពក្រីក្រពី ២៥,៨ភាគរយ នៅឆ្នាំ២០១០ មកត្រឹម ១៩,៥ភាគរយ នៅឆ្នាំ២០១៥ ខាងមុខនេះ។